ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# អង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា ឆ្នាំ ២០២១-២២

## របាយការណ៍សូចនាករសង្ខេប


វិទ្យាស្ថានជាតិស្ថិតិ
ក្រសួងផែនការ
ភ្នំពេញ កម្ពុជា

អគ្គនាយកដ្ឋានបច្ចេកទេសសុខាភិបាល
ក្រសួងសុខាភិបាល
ភ្នំពេញ កម្ពុជា



ខែ មិថុនា ឆ្នាំ ២០២២

អង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា (CDHS ២០២១-២២) អនុវត្តគម្រោងដោយវិទ្យាស្ថានជាតិស្ថិតិ (NIS) ក្រោមកិច្ចសហការជាមួយក្រសួងសុខាភិបាល ICF ផ្តល់ជំនួយបច្ចេកទេសតាមរយៈកម្មវិធី DHS ដែលជាគម្រោងដែលផ្តល់ មូលនិធិដោយ USAID សម្រាប់ផ្តល់ការគាំទ្រ និងជំនួយបច្ចេកទេសក្នុងការអនុវត្តអង្កេតប្រជាសាស្ត្រ និងសុខភាពនៅក្នុងប្រទេសនានាទូទាំងពិភពលោក។

ព័ត៌មានបន្ថែមអំពី CDHS ២០២១-២២ អាចទំនាក់ទំនងពីវិទ្យាស្ថានជាតិស្ថិតិ ។ អគារលេខ ៣៨៦ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងកេងកង ១ ចំការមន រាជធានីភ្នំពេញ កម្ពុជា; ទូរស័ព្ទ៖ (៨៥៥) ២៣-២១៣៦៥០ អ៊ីមែល៖ linahang2002@gmail.com អ៊ីធឺណិត៖ www.nis.gov.kh ឬអគ្គនាយកដ្ឋានសុខាភិបាលក្រសួងសុខាភិបាល លេខ ៨០ មហាវិថីសម្តេច ប៉ែន នុត (២៨៩) សង្កាត់បឹងកក់២ ទួលគោក រាជធានីភ្នំពេញ កម្ពុជា ទូរស័ព្ទ៖ (៨៥៥) ២៣-៨៨៥៩៧០/២៣-៨៨៤៩០៩ អ៊ីមែល៖ webmaster@moh.gov.kh; អ៊ីនធឺណិត៖ www.moh.gov.kh ។

ព័ត៌មានអំពីកម្មវិធី DHS អាចទទួលបានពី ICF ៥៣០ Gaither Road Suite ៥០០ Rockville, MD ២០៨៥០ USA ( ទូរស័ព្ទ៖ +១-៣០១-៤០៧-៦៥០០ ទូរសារ៖ +១-៣០១-៤០៧-៦៥០១ អ៊ីមែល៖ ព័ត៌មាន @DHSprogram.com អ៊ីនធឺណិត៖ www.DHSprogram.com ) ។

ខ្លឹមសារក្នុងរបាយការណ៍នេះគឺជាការទទួលខុសត្រូវទាំងស្រុងរបស់ NIS និង ICF ហើយមិនឆ្លុះបញ្ចាំងពីទស្សនៈរបស់ USAID រដ្ឋាភិបាលសហរដ្ឋអាមេរិក ឬទីភ្នាក់ងារផ្តល់ជំនួយផ្សេងទៀតឡើយ។

អនុសាសន៍ណែនាំ៖
វិទ្យាស្ថានជាតិស្ថិតិ (NIS) [កម្ពុជា] ក្រសួងសុខាភិបាល (MOH) [កម្ពុជា] និង ICF ២០២២ អង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា ២០២១-២២ របាយការណ៍សូចនាករស្នូល។ ភ្នំពេញ កម្ពុជា និង Rockville រដ្ឋ Maryland សហរដ្ឋអាមេរិក ៖ NIS, MOH, និង ICF ។

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

# អង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា
# ឆ្នាំ ២០២១-២២
## របាយការណ៍សូចនាករស្នូល


**វិទ្យាស្ថានជាតិស្ថិតិ**
**ភ្នំពេញ កម្ពុជា**

**ក្រសួងសុខាភិបាល**
**ភ្នំពេញ កម្ពុជា**

The DHS Program
ICF
Rockville, Maryland, USA



**ខែ មិថុនា ឆ្នាំ ២០២២**

# មាតិការ

តារាង និងរូបភាព.....v
អក្សរកាត់ និងពាក្យកាត់.....vi
អារម្ភកថា.....៩
**១ សេចក្តីផ្តើម**.....១០
១.១ គោលបំណងអង្កេត.....១០
**២ ប្រតិបត្តិការអង្កេត**.....១១
២.១ វិធីសាស្ត្ររៀបចំសំណាកគំរូ.....១១
២.២ កម្រងសំណួរ.....១២
២.៣ ការវាស់វែងមនុស្សមាត្រ.....១៣
២.៤ អង្កេតសាកល្បង.....១៤
២.៤.១ បណ្តុះបណ្តាលមន្ត្រីសម្ភាសន៍.....១៤
២.៥ បណ្តុះបណ្តាលមន្ត្រីមូលដ្ឋាន.....១៥
២.៥.១ ការបណ្តុះបណ្តាលកម្រងសំណួរ.....១៥
២.៥.២ការបណ្តុះបណ្តាលមនុស្សមាត្រ.....១៦
២.៥.៣ការបណ្តុះបណ្តាល CAPI.....១៦
២.៦ ប្រតិបត្តិការមូលដ្ឋាន.....១៧
២.៧ ការកែច្នៃទិន្នន័យ.....១៨
**៣ លទ្ធផលបឋម**.....១៩
៣.១ អត្រាឆ្លើយតប.....១៩
៣.២ ចរឹតលក្ខណៈអ្នកផ្តល់ចម្លើយ.....២០
៣.៣ លទ្ធភាពមានកូន.....២២
៣.៤ លទ្ធភាពមានកូនវ័យជំទង់.....២៤
៣.៥ ចំណង់ចំណូលចិត្តបង្កើតកំណើត.....២៥
៣.៦ ផែនការគ្រួសារ.....២៧
៣.៦.១ ការប្រើប្រាស់វិធីសាស្ត្រពន្យាកំណើត.....២៧
៣.៦.២តម្រូវការ និងផែនការគ្រួសារ.....៣១
៣.៧ មរណភាពកុមារ.....៣៤
៣.៨ ការថែទាំសុខភាពមាតា.....៣៥
៣.៨.១ការថែទាំផ្ទៃពោះមុនសម្រាល.....៣៨

៣.៨.២ការចាក់ថ្នាំតេតាណុស ........................................ ៣៨
៣.៨.៣ការថែទាំពេលសម្រាល ........................................ ៣៩
៣.៨.៤ការថែទាំក្រោយពេលសម្រាលកូន ........................................ ៤០
៣.៩ វិសាលភាពគ្របដណ្តប់ការចាក់វ៉ាក់សាំង ........................................ ៤០
៣.១០ ការថែទាំ និងព្យាបាលជម្ងឺកុមារ ........................................ ៤៥
៣.១១ ស្ថានភាពអាហារូបត្ថម្ភរបស់កុមារ ........................................ ៤៨
៣.១២ ការបំបៅទឹកដោះ ទារក និងកុមារ ........................................ ៥៣
៣.១៣ ចំណេះដឹងអំពីមេរោគអេដស៍/HIV ........................................ ៥៥
៣.១៣.១ចំណេះដឹងពីវិធីបង្ការចំណោមយុវជន ........................................ ៥៥
៣.១៣.២ឥរិយាបទនៃការរួមភេទ ........................................ ៥៧
៣.១៣.៣ការធ្វើតេស្តរកមេរោគអេដស៍ ........................................ ៦១
៣.១៤ មរណភាពមាតា ........................................ ៦៦
៣.១៥ ការដាក់ពិន័យលើកុមារ ........................................ ៦៧
**ឯកសារយោង ........................................ ៦៩**

# តារាង និងរូប


| | | |
|---|---|---|
| តារាង ១ | លទ្ធផលនៃការសម្ភាសន៍គ្រួសារ និងបុគ្គល | ១៩ |
| តារាង ២ | ចរឹតលក្ខណៈនៃអ្នកផ្តល់ចម្លើយ | ២០ |
| តារាង ៣ | លទ្ធភាពបង្កើតកូនបច្ចុប្បន្ន | ២៣ |
| តារាង ៤ | ការមានគភ៌ និងមាតុភាពវ័យជំទង់ | ២៤ |
| តារាង ៥ | ចំណង់ចំណូលចិត្តបង្កើតកំណើតរបស់ស្ត្រីតាមចំនួនកូនកើតរស់ | ២៦ |
| តារាង ៦ | វិធីសាស្ត្រពន្យារកំណើតបច្ចុប្បន្នតាមចរឹតលក្ខណៈអង្កេត | ២៨ |
| តារាង ៧ | ជម្រើស និងតម្រូវការសម្រាប់ផែនការគ្រួសារក្នុងចំណោមស្ត្រីបច្ចុប្បន្នរៀបការ និងសកម្មភាពរួមភេទស្ត្រីមិនទាន់រៀបការ | ៣២ |
| តារាង ៨ | អត្រាមរណភាពកុមារ | ៣៥ |
| តារាង ៩ | សូចនាករថែទាំសុខភាពមាតា | ៣៦ |
| តារាង ១០ | ការចាក់ថ្នាំបង្ការតាមលក្ខណៈអង្កេត | ៤២ |
| តារាង១១ | ការព្យាបាលរោគសញ្ញា ARI គ្រុនក្តៅ និងរាករូស | ៤៦ |
| តារាង ១២ | ស្ថានភាពអាហារូបត្ថម្ភកុមារ | ៥០ |
| តារាង ១៣ | សូចនាករការផ្តល់អាហារដល់ទារក និងកុមារតូច(IYCF) | ៥៤ |
| តារាង ១៤ | ចំណេះដឹងអំពីវិធីសាស្ត្រការពារមេរោគអេដស៍ក្នុងចំណោមយុវជន | ៥៦ |
| តារាង ១៥.១ | ដៃគូរួមភេទច្រើន និងការរួមភេទមានហានិភ័យខ្ពស់ក្នុងរយៈពេល ១២ ខែចុងក្រោយ៖ ស្ត្រី | ៥៧ |
| តារាង ១៥.២ | ដៃគូរួមភេទច្រើន និងការរួមភេទមានហានិភ័យខ្ពស់ក្នុងរយៈពេល ១២ ខែចុងក្រោយ៖ បុរស | ៥៩ |
| តារាង ១៦.១ | វិសាលភាពគ្របដណ្តប់នៃការធ្វើតេស្តន៍រកមេរោគអេដស៍៖ ស្ត្រី | ៦២ |
| តារាង ១៦.២ | វិសាលភាពគ្របដណ្តប់នៃការធ្វើតេស្តន៍រកមេរោគអេដស៍៖ បុរស | ៦៤ |
| តារាង ១៧ | អនុបាទមរណមាតា | ៦៦ |
| តារាង ១៨ | ការដាក់ពិន័យលើកុមារ | ៦៨ |
| តារាង១៩ | ឥរិយាចំពោះការដាក់លពិន័យលើរាងកាយ | ៦៨ |

| | | |
|---|---|---|
| រូប ១ | និន្នាការអត្រាលទ្ធភាពមានកូនសរុបតាមតំបន់ | ២៣ |
| រូប ២ | និន្នាការនៃការប្រើប្រាស់ តម្រូវការ និងត្រូវការសម្រាប់ផែនការគ្រួសារ | ៣៤ |
| រូប ៣ | និន្នាការនៃអត្រាមរណភាពកុមារ | ៣៥ |
| រូប ៤ | និន្នាការអ្នកជំនួយក្នុងពេលសម្រាល | ៣៩ |
| រូប ៥ | និន្នាការនៃការចាក់វ៉ាក់សាំងកុមារ | ៤៥ |
| រូប ៦ | និន្នាការនៃស្ថានភាពអាហារូបត្ថម្ភរបស់កុមារ | ៥៣ |
| រូប ៧ | និន្នាការនៃការបំបៅកូនដោយទឹកដោះម្តាយតែមួយមុខ | ៥៥ |

# អក្សរកាត់ និងពាក្យកាត់

| | |
|---|---|
| AIDS | ជំងឺអេដស៍ |
| ANC | ការថែទាំមុនពេលសម្រាល |
| ARI | មេរោគផ្លូវដង្ហើមស្រួចស្រាវ |
| ASFR | អត្រាលទ្ធភាពមានកូនតាមអាយុជាក់លាក់ ថ្នាំបង្កជំងឺរបេង |
| BCG | ថ្នាំបង្ការជំងឺរបេង |
| CAPI | ការសម្ភាសន៍បុគ្គលប្រើកុំព្យូទ័រជំនួយ |
| CBR | អត្រាកំណើតដុល |
| CSPro | ការកែច្នៃទិន្នន័យជំរឿន និងអង្កេត |
| DHS | អង្កេតប្រជាសាស្ត្រ និងសុខភាព |
| DPT | វ៉ាក់សាំងការពារជំងឺខាន់ស្លាក់ ក្អកមាន់ និងតេតាណូស |
| EA | មណ្ឌលសម្ភាសន៍ |
| HepB | ជំងឺរលាកថ្លើមប្រភេទ B |
| Hib | ជំងឺរលាកស្រោមខួរក្បាលបង្កដោយមេរោគហ៊ីប |
| HIV | មេរោគអេដស៍ |
| IFSS | ប្រព័ន្ធស្ទ្រីម (បញ្ជូន) ឯកសារអ៊ីនធឺណិត |
| IPV | វ៉ាក់សាំង poliomyelitis អសកម្ម |
| IUD | កងដាក់ក្នុងស្បូន |
| IYCF | ការផ្តល់អាហារទារកនិងកុមារតូច |
| LAM | វិធីពន្យាកំណើតដោយការបំបៅដោះកូនដោយទឹកដោះម្តាយ |
| MOH | ក្រសួងសុខាភិបាល |
| MMR | អនុបាទមរណភាពមាតា |
| NN | មរណភាពទារកទើបកើត |
| OPV | វ៉ាក់សាំងជំងឺស្វិតដៃជើង |
| ORS | ជាតិប្រៃសម្រាប់ជាតិទឹកក្នុងមាត់ |
| PCV | វ៉ាក់សាំងការពារជំងឺរលាកសួត |
| PNC | ការថែទាំក្រោយសម្រាល |
| PNN | មរណភាពក្រោយប្រសូត |
| PSU | ឯកតាសំណាកគំរូបឋម |
| RV | វ៉ាក់សាំង rotavirus |
| SD | គម្លាតស្តង់ដារ |
| SDG | គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព |
| SDM | វិធីសាស្ត្រពន្យាកំណើតរាប់ថ្ងៃស្តង់ដារ |

| | |
|---|---|
| SP | sulfadoxine-pyrimethamine |
| STI | ជំងឺកាមរោគ |
| TFR | អត្រាលទ្ធភាពមានកូនសរុប |
| UNFPA | អង្គការមូលនិធិសហប្រជាជាតិសម្រាប់ប្រជាជន |
| USAID | ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិសហរដ្ឋអាមេរិក |
| WHO | អង្គការសុខភាពពិភពលោក |

# អារម្ភកថា

អង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា (CDHS ២០២១-២២) អនុវត្តគម្រោងដោយវិទ្យាស្ថានជាតិស្ថិតិ (NIS) ក្រោមកិច្ចសហការជាមួយក្រសួងសុខាភិបាល ។ បាយការណ៍សូចនាករស្នូល (KIR) នេះបង្ហាញពីលទ្ធផលបឋមពី CDHS ២០២១-២២ ។ លទ្ធផលបឋមពីអង្កេតនឹងត្រូវបានប្រើដោយអ្នកតាក់តែងគោលនយោបាយដើម្បីវាយតម្លៃពីស្ថានភាពប្រជាសាស្ត្រ និងសុខភាពប្រជាជនកម្ពុជាក្នុងគោលបំណងដើម្បីបង្កើតគោលនយោបាយប្រជាសាស្ត្រ និងសុខភាព និងកម្មវិធីឱ្យបានសមស្របមួយនៅកម្ពុជា។ របាយការណ៍ចុងក្រោយនឹងផ្តល់ព័ត៌មានលម្អិតជូនក្នុងពេលដ៏ខ្លីខាងមុខ ។

អង្កេតនេះទទួលបានការគាំទ្រផ្នែកហិរញ្ញវត្ថុពីរាជរដ្ឋាភិបាលកម្ពុជា(RGC) ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិសហរដ្ឋអាមេរិក (USAID) ទីភ្នាក់ងារអភិវឌ្ឍន៏អន្តរជាតិអាល្លឺម៉ង់ (GIZ)) ជំនួយអូស្ត្រាលី (Australian Aids) អង្គការមូលនិធិសហប្រជាជាតិសម្រាប់ប្រជាជន (UNFPA) មូលនិធិសហប្រជាជាតិសម្រាប់កុមារ (UNICEF) កម្មវិធីស្បៀងអាហារពិភពលោក (WFP)។ ខ្ញុំសូមថ្លែងអំណរគុណដល់ ICF ដែលផ្តល់ជំនួយបច្ចេកទេសសម្រាប់ការអង្កេតនេះ។ អង្កេតនេះសម្រេចទៅបានគឺ ដោយអាស្រ័យការយកចិត្តទុកដាក់ពីមន្ត្រីគ្រប់ជាន់ថ្នាក់របស់វិទ្យាស្ថានជាតិស្ថិតិ(NIS) និងក្រសួងសុខាភិបាល(MOH) ចូលរួមរៀបចំការងារបច្ចេកទេសជាមន្ត្រីសម្ភាសន៍ ជាមន្ត្រីត្រួតពិនិត្យ និងជាអ្នកសម្របសម្រួលគ្រប់ដំណាក់កាលអង្កេតប្រកបដោយការទទួលខុសត្រូវខ្ពស់។

ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត **ឆាយ ថន** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ ឯកឧត្តមសាស្ត្រាចារ្យ **អេង ហួត** រដ្ឋលេខាធិការក្រសួងសុខាភិបាល ឯកឧត្តម **លេខ ផាលី** រដ្ឋលេខាធិការក្រសួងផែនការ ឯកឧត្តម **ហោ ដារិទ្ធ** រដ្ឋលេខាធិការក្រសួងផែនការ សមាជិកគណៈកម្មាធិការប្រតិបត្តិ និងគណៈកម្មាធិការបច្ចេកទេស ដែលបានរួមចំណែកធ្វើឲ្យការអង្កេតនេះទទួលបានជោគជ័យ។ ខ្ញុំសូមកោតសរសើរយ៉ាងខ្លាំងចំពោះក្រុមការងាររបស់វិទ្យាស្ថានជាតិស្ថិតិ និងក្រសួងសុខាភិបាលនិងមន្ត្រីរាជធានីខេត្ត ដែលបានធ្វើការដោយការយកចិត្តទុកដាក់ និងសាទរក្នុងការធ្វើឱ្យការអង្កេតសម្រេចបានជោគជ័យ។

ជាចុងក្រោយខ្ញុំសូមថ្លែងអំណរគុណចំពោះពិសេសដល់អាជ្ញាធរដែនដីពាក់ព័ន្ធ និងមន្ត្រីចូលរួមទាំងអស់ចំពោះការចំណាយពេលវេលាដ៏មានតម្លៃ ដើម្បីធ្វើឱ្យអង្កេតនេះអាចធ្វើទៅបានដោយជោគជ័យ។

ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា
ទទួលបន្ទុកអគ្គនាយកវិទ្យាស្ថានជាតិស្ថិតិ

**ជំទាវ ហង់ លីណា**

រដ្ឋលេខាធិការ
ក្រសួងសុខាភិបាល

**ឯកឧត្តម វេជ្ជ. ឡូ វាសនាគិរី**

# សេចក្ដីផ្ដើម ១

អង្កេតប្រជាសាស្ត្រនិង សុខភាពកម្ពុជាឆ្នាំ ២០២១-២២ (CDHS) គឺជាសេរីអង្កេតលើកទី៥ដែលបានអនុវត្តន៍ធ្វើចាប់តាំងពីឆ្នាំ ២០០០ ២០០៥ ២០១០ និង២០១៤ ។ វិទ្យាស្ថានជាតិស្ថិតិ (NIS) បានសហការជាមួយក្រសួងសុខាភិបាលដឹកនាំក្នុងការធ្វើអង្កេតនេះ។ អង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជាឆ្នាំ ២០២១-២២ បានចាប់ផ្ដើមប្រតិបត្តិការស្រង់ទិន្នន័យចាប់ពីថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ២០២១ ដល់ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២២ ។ CDHS ២០២១-២២ ប្រើប្រាស់ថវិកាគាំទ្រដោយរាជរដ្ឋាភិបាលកម្ពុជា និងចូលរួមចំណែកដោយភ្នាក់ងារអភិវឌ្ឍន៏អន្តរជាតិអាមេរិក (USAID) ភ្នាក់ងារអភិវឌ្ឍន៏អន្តរជាតិអាល្លឺម៉ង់ (GIZ) ជំនួយអូស្ត្រាលី (Australian Aids) មូលនិធិសហប្រជាជាតិសម្រាប់ប្រជាជន (UNFPA) មូលនិធិសហប្រជាជាតិសម្រាប់កុមារ (UNICEF) កម្មវិធីស្បៀងអាហារពិភពលោក(WFP) ។ ICF អន្តរជាតិផ្ដល់ជំនួយបច្ចេកទេសទៅលើប្រតិបត្តិការនេះតាមរយៈកម្មវិធីរង្វាស់អង្កេតប្រជាសាស្ត្រនិងសុខភាព (MEASURE DHS) សម្រាប់បណ្ដាប្រទេសមួយចំនួនប្រមូលទិន្នន័យសម្រាប់ត្រួតពិនត្យ និងវាយតម្លៃការប្រែប្រួលប្រជាសាស្ត្រ សុខភាព និងអាហាររូបត្ថម្ភ ។

របាយការណ៍សូចនាករស្នូលនេះ បង្ហាញជូនតែលទ្ធផលសំខាន់ៗមួយចំនួនពីអង្កេត CDHS ២០២១-២២ ប៉ុណ្ណោះ។ របាយការណ៍វិភាគទិន្នន័យលម្អិតទូលំទូលាយនឹងបោះពុម្ពនិងផ្សព្វផ្សាយនៅក្នុងត្រីមាសទី៤ ខាងមុខ។

## ១.១ គោលបំណងអង្កេត

គោលបំណងចម្បង CDHS ២០២១-២២ គឺដើម្បីផ្ដល់នូវការការធ្វើបច្ចុប្បន្នភាពប៉ាន់ប្រមាណមូលដ្ឋានសូចនាករប្រជាសាស្ត្រ និងសុខភាព។ ជាពិសេស CDHS ២០២១-២២ បានប្រមូលព័ត៌មានស្ដីពីលទ្ធភាពមានកូន ការយល់ដឹង និងការប្រើប្រាស់វិធីសាស្ត្រពន្យាកំណើត ផែនការគ្រួសារ ការអនុវត្តការបំបៅកូនដោយទឹកដោះម្ដាយ ស្ថានភាពអាហារូបត្ថម្ភរបស់ស្ត្រី និងកុមារ សុខភាពមាតា និងទារក អត្រាមរណភាពមនុស្សពេញវ័យ និងកុមារ ការពង្រឹងសិទ្ធិអំណាចស្ត្រី អំពើហិង្សាក្នុងគ្រួសារ ការយល់ដឹង និងអាកប្បកិរិយាទាក់ទងនឹងមេរោគអេដស៍/ជំងឺអេដស៍ និងជំងឺឆ្លងតាមផ្លូវភេទផ្សេងទៀត (STIs) និងបញ្ហាទាក់ទងនឹងសុខភាពផ្សេងទៀតដូចជាការជក់បារីជាដើម។

ព័ត៌មានដែលប្រមូលបានពី CDHS ២០២១-២២ មានគោលបំណងដើម្បីជួយអ្នករៀបចំគោលនយោបាយ និងអ្នកគ្រប់គ្រងកម្មវិធី អ្នករៀបចំកម្មវិធី និងអ្នកវាយតម្លៃកម្មវិធី និងរៀបចំយុទ្ធសាស្ត្រសម្រាប់ការកែលម្អសុខភាពរបស់ប្រជាជនរបស់ប្រទេស។ CDHS ២០២១-២២ ក៏ផ្ដល់សូចនាករពាក់ព័ន្ធទៅនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDGs) សម្រាប់កម្ពុជាផងដែរ។

# ប្រតិបត្តិការអង្កេត ២

## ២.១ វិធីសាស្ត្ររៀបចំសំណាកគំរូ

អង្កេតប្រជាសាស្ត្រនិង សុខភាពកម្ពុជាឆ្នាំ ២០២១-២២ (CDHS) ប្រើប្រាស់ក្របខ័ណ្ឌសំណាកគំរូពីជំរឿនទូទៅប្រជាជនកម្ពុជាឆ្នាំ ២០១៩ (GPC) ដែលត្រូវបានធ្វើឡើងនៅឆ្នាំ២០១៩ ដោយវិទ្យាស្ថានជាតិស្ថិតិ (NIS)។ ក្របខ័ណ្ឌសំណាកគំរូនេះគ្របដណ្តប់ពេញលេញទៅលើបញ្ជីមណ្ឌលជំរឿន Enumeration Areas (EAs) នៅទូទាំងប្រទេសដែលផ្តល់ដោយ NIS ដើម្បីជ្រើសរើសសំណាកគំរូសម្រាប់អង្កេត CDHS ។ បញ្ជីមណ្ឌលជំរឿន EA គឺជាភូមិទាំងមូល ឬជាផ្នែកមួយនៃភូមិមួយដែលត្រូវបានរៀបចំឡើងសម្រាប់ធ្វើជំរឿនឆ្នាំ២០១៩ សម្រាប់រាប់មនុស្សទាំងអស់ក្នុងជំរឿន។

សំណាកគំរូអង្កេត CDHS ២០២១-២២ រៀបចំជ្រើសរើសជាពីរដំណាក់កាលផ្សេងគ្នាដែលអាចអនុញ្ញាតឲ្យធ្វើការប៉ាន់ប្រមាណសូចនាករស្នូលនៅកម្រិតជាតិជាពិសេសទីប្រជុំជន និងជនបទទូទាំង ២៥ រាជធានី ខេត្ត។ ដំណាក់កាលបឋមគឺជ្រើសរើសចង្កោម (clusters) សំណាកគំរូមណ្ឌលជំរឿនដែលបានរៀបចំឡើងសម្រាប់ធ្វើជំរឿនឆ្នាំ២០១៩ ។ សំណាកគំរូមណ្ឌលជំរឿនចំនួន ៧០៩ ត្រូវបានជ្រើសរើសក្នុងនោះទីប្រជុំជនមាន ២៤១ និង៤៦៨ ជនបទ ។ ជំរឿនទូទៅប្រជាជនកម្ពុជាឆ្នាំ ២០១៩ បានរៀបចំជាចំណាត់ថ្នាក់ទីប្រជុំជនឡើងវិញដែល ២០% នៃមណ្ឌលជំរឿននៅជនបទត្រូវចាត់បញ្ចូលជាទីប្រជុំជន ។

ដំណាក់កាលបន្ទាប់គឺជ្រើសរើសសំណាកគំរូគ្រួសារ។ សំណាកគំរូមណ្ឌលជំរឿនដែលបានជ្រើសរើសនៅដំណាក់កាលបឋមទាំងអស់ត្រូវបានចុះបញ្ជីគ្រួសារដែលមាននៅក្នុងមណ្ឌលជំរឿនជាក់ស្តែងចាប់ពីខែមេសាដល់ខែសីហាឆ្នាំ២០២១ បន្ទាប់មកសំណាកគំរូគ្រួសារត្រូវបានជ្រើសរើសដោយចៃដន្យពីសម្រង់បញ្ជីគ្រួសារដែលបានចុះបញ្ជីរួចនោះ។ មណ្ឌលជំរឿនគ្រួសារត្រូវបានជ្រើសរើសចេញពីមណ្ឌលជំរឿននិមួយៗជារួម ២១.២៧០ គ្រួសារត្រូវបានជ្រើសរើសសម្រាប់អង្កេតនេះ។ ដោយសារទំហំសំណាកគំរូស្មើគ្នាសម្រាប់ខេត្តនិមួយៗ សំណាកគំរូមិនត្រូវបានធ្វើសម្រាប់កម្រិតជាតិឡើយ ហើយមេគុណសំណាកគំរូត្រូវបានគណនា និងបញ្ចូលទៅក្នុងកម្រងទិន្នន័យ ដូច្នេះលទ្ធផលនឹងមានសមាមាត្រនៅថ្នាក់ជាតិ។

គ្រប់ស្ត្រីដែលមានអាយុពី ១៥-៤៩ មានក្នុងគ្រួសារត្រូវបានជ្រើសរើសជាសំណាកគំរូបើទោះជាសមាជិកអចិន្ត្រៃយ៍ ឬជាភ្ញៀវក្តីដែលបានស្នាក់នៅក្នុងគ្រួសារមុនយប់ថ្ងៃធ្វើអង្កេតត្រូវបានជ្រើសរើសសម្រាប់សម្ភាសន៍ទាំងអស់។ សំណាកគំរូមានពាក់កណ្តាលនៃគ្រួសារទាំងអស់ត្រូវបានជ្រើសរើសសម្រាប់ការសម្ភាសន៍បុរសដែលមានអាយុពី ១៥-៤៩ បើទោះជាសមាជិកអចិន្ត្រៃយ៍ ឬជាភ្ញៀវក្តីបើពួកគេបានស្នាក់នៅក្នុងគ្រួសារមុនយប់ថ្ងៃធ្វើអង្កេតត្រូវបានជ្រើសរើសសម្រាប់អង្កេត។ បន្ថែមលើសពីនេះទៅទៀតគ្រួសារដែលមិនត្រូវបានសម្ភាសន៍បុរសនឹងត្រូវបានជ្រើសរើសសម្រាប់វាស់កម្ពស់ ថ្លឹងទម្ងន់ វាស់ដើមដៃលើស្ត្រីដែលមានអាយុពី ១៥-៤៩ ឆ្នាំ និងកុមារអាយុតិចជាង ៥ ឆ្នាំ ។

## ២.២ កម្រងសំណួរ

កម្រងសំណួរចំនួនប្រាំត្រូវបានប្រើប្រាស់សម្រាប់ការអង្កេត CDHS ២០២១-២២ រួមមានកម្រងសំណួរគ្រួសារ កម្រងសំណួរស្ត្រី កម្រងសំណួរបុរស កម្រងសំណួរមនុស្សមាត្រ និងកម្រងសំណួរមន្ត្រីមូលដ្ឋាន។ កម្រងសំណួរទាំងនេះផ្អែកលើបទដ្ឋានកម្មវិធីអង្កេតប្រជាសាស្ត្រ និងសុខភាពពិភពលោកជំនាន់ទី៨ (DHS-៨) ។ កម្រងសំណួរទាំងនេះឆ្លុះបញ្ចាំងបញ្ហាពាក់ព័ន្ធប្រជាពស្ត្រ និងសុខភាពនៅប្រទេសកម្ពុជា។ កម្រងសំណួរទាំងនេះត្រូវបានអនុម័តជាបន្តបន្ទាប់ក្នុងកិច្ចប្រជុំបច្ចេកទេសរវាងភាគីដែលពាក់ព័ន្ធក្នុងជួររាជរដ្ឋាភិបាល ទីភ្នាក់ងារអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាល និងម្ចាស់ស់ជំនួយអន្តរជាតិ។ សេចក្តីព្រាងចុងក្រោយនៃតារាងសំណួរនេះត្រូវបានពិភាក្សានៅក្នុងកិច្ចប្រជុំមួយដែលរៀបចំដោយ NIS។ ឯកសារណែនាំត្រូវបានត្រួតពិនិត្យដោយគណៈកម្មាធិការក្រមសីលធម៌ជាតិសម្រាប់ការស្រាវជ្រាវសុខភាព (NECHR) និងត្រួតពិនិត្យឡើងវិញដោយក្រុមប្រឹក្សាត្រួតពិនិត្យស្ថាប័ន ICF។ បន្ទាប់ពីកម្រងសំណួរទាំងនេះត្រូវបានអនុម័តពីភាសាអង់គ្លេសរួចត្រូវបានបកប្រែទៅជាភាសាខ្មែរ។ CDHS ២០២១-២២ ប្រើកម្មវិធីស្រង់ទិន្នន័យប្រើកុំព្យូទ័រជំនួយក្នុងការសម្ភាសន៍(CAPI) ។

កម្រងសំណួរគ្រួសារត្រូវបានប្រើប្រាស់ដើម្បីស្រង់ព័ត៌មានពីគ្រប់សមាជិកគ្រួសារអចិន្ត្រៃយ៍ និងភ្ញៀវរបស់គ្រួសារដែលត្រូវបានជ្រើសរើសសម្ភាសន៍។ ព័ត៌មានមូលដ្ឋានត្រូវបានប្រមូលមានចរឹតលក្ខណៈរបស់បុគ្គលម្នាក់ៗត្រូវបានស្រង់ចូលរួមមាន អាយុ ភេទ ការអប់រំ និងទំនាក់ទំនងទៅនឹងមេគ្រួសារ។ សម្រាប់កុមារអាយុក្រោម ១៨ ឆ្នាំ ស្ថានភាពរស់រានមានជីវិតរបស់ឳពុកម្តាយបានកំណត់ ។

ទិន្នន័យអំពីអាយុ ភេទ និងស្ថានភាពអាពាហ៍ពិពាហ៍របស់សមាជិកគ្រួសារត្រូវបានប្រើប្រាស់ដើម្បីកំណត់អត្តសញ្ញាណស្ត្រី និងបុរសដែលមានសិទ្ធិសម្រាប់ការសម្ភាសន៍បុគ្គល។ កម្រងសំណួរគ្រួសារក៏បានប្រមូលព័ត៌មានអំពីលក្ខណៈនៃអង្គភាពលំនៅដ្ឋានរបស់គ្រួសារដូចជាប្រភពទឹកផឹក។ ប្រភេទនៃបង្គន់អនាម័យ សម្ភារៈប្រើប្រាស់សម្រាប់កម្រាលឥដ្ឋ ជញ្ជាំង និងដំបូល និងភាពជាម្ចាស់នៃសម្ភារៈប្រើប្រាស់បានយូរផ្សេងៗ។ លើសពីនេះទៀត ម៉ូឌុលស្តីពីពិការភាព និងកាដាក់ពិន័យកុមារត្រូវបានបញ្ចូលទៅក្នុងកម្រងសំណួរនេះផងដែរ ។

កម្រងសំណួររបស់ស្ត្រីត្រូវបានប្រើដើម្បីប្រមូលព័ត៌មានពីស្ត្រីដែលមានសិទ្ធិទាំងអស់ដែលមានអាយុពី ១៥-៤៩ ឆ្នាំ។ ស្ត្រីទាំងនេះត្រូវបានសួរសំណួរលើប្រធានបទដូចខាងក្រោមៈ

- ចរឹតលក្ខណៈអង្កេត (មានអាយុ ការអប់រំ និងប្រព័ន្ធផ្សព្វផ្សាយ)
- ប្រវត្តិនៃការមានផ្ទៃពោះ និងមរណភាពកុមារ
- ការយល់ដឹង ការប្រើប្រាស់ការពន្យាកំណើត និងប្រភព ផែនការគ្រួសារ
- ការពិនិត្យផ្ទៃពោះមុនសម្រាល ពេលសម្រាលកូន និងក្រោយសម្រាល
- ការចាក់វ៉ាក់សាំង និងជំងឺកុមារ
- ការអនុវត្តការបំបៅកូនដោយទឹកដោះម្តាយ និងការបំបៅកូន

- របបអាហារអេប្បបរមារបស់ស្ត្រី
- អាពាហ៍ពិពាហ៍ និងសកម្មភាពផ្លូវភេទ
- ចំណូលចិត្តក្នុងការមានកូន (រួមទាំងបំណងប្រាថ្នាចង់បានកូន និងចំនួនកូនដែលចង់បាន)
- ការងាររបស់ស្ត្រី និងចរិតលក្ខណៈអង្កេតរបស់ប្តី
- ចំណេះដឹង ការយល់ដឹង និងឥរិយាបទទាក់ទងនឹងមេរោគអេដស៍/ជំងឺអេដស៍ និងជំងឺឆ្លងតាមផ្លូវភេទផ្សេងទៀត (STIs)
- ចំណេះដឹង ការយល់ដឹង និងឥរិយាបទទាក់ទងនឹងបញ្ហាសុខភាពផ្សេងទៀត (ឧ. ការជក់បារី)
- មរណភាពមាតា និងមនុស្សពេញវ័យ
- អំពើហឹង្សាក្នុងគ្រួសារ

កម្រងសំណួរបុរស ត្រូវបានប្រើប្រាស់ដើម្បីស្រង់ព័ត៌មានពីសំណាកគំរូគ្រួសារអង្កេតលើបុរសបុរសអាយុ ១៥-៤៩ ឆ្នាំ។ កម្រងសំណួររបស់បុរសបានប្រមូលព័ត៌មានជាច្រើនដូចគ្នានឹងកម្រងសំណួររបស់ស្ត្រី ប៉ុន្តែមានរយៈពេលខ្លីជាង ដោយសារសំណួរលម្អិតពីប្រវត្តិបន្តពូជ ឬសំណួរលម្អិតអំពីសុខភាពមាតា និងទារក។ កម្រងសំណួរមនុស្សមាត្រ (Biomarker) ត្រូវបានប្រើដើម្បីកត់ត្រាលទ្ធផលនៃការវាស់វែងមនុស្សមាត្រ (anthropometry) សម្រាប់ស្ត្រី និងកុមារ។ កម្រងសំណួរនេះត្រូវបានគ្រប់គ្រងតែចំពោះគំរូរងដែលត្រូវបានជ្រើសរើសសម្រាប់សមាសធាតុមនុស្សមាត្រប៉ុណ្ណោះ។

កម្រងសំណួរមន្ត្រីមូលដ្ឋាន បានកត់ត្រាព័ត៌មានសាវតាមន្ត្រីសម្ភាសន៍ដែលនឹងបម្រើជាឧបករណ៍ក្នុងការវិភាគគុណភាពទិន្នន័យ។ អ្នកសំភាសន៍ម្នាក់ៗបានបំពេញកម្រងសំណួរអ្នកបំពេញការងារដែលគ្រប់គ្រងដោយខ្លួនឯងបន្ទាប់ពីការជ្រើសរើសចុងក្រោយនៃមន្ត្រីសម្ភាសន៍ និងមុនពេលចុះធ្វើការនៅតាមគោលដៅអង្កេត។ មិនមានអត្តសញ្ញាណផ្ទាល់ខ្លួនត្រូវបានភ្ជាប់ទៅនឹងឯកសារទិន្នន័យមន្ត្រីត្រួតពិនិត្យ និងសម្ភាសន៍នៅក្នុង CDHS ២០២១-២២ នេះឡើយ ។

មន្ត្រីសម្ភាសន៍បានប្រើថេប្លេត (Tablet) សម្រាប់ការប្រមូលទិន្នន័យ។ ថេប្លេតត្រូវបានបំពាក់ដោយបច្ចេកវិទ្យា Bluetooth® ដើម្បីបើកដំណើរការផ្ទេរឯកសារអេឡិចត្រូនិកពីចម្ងាយ ដូចជាការចាត់តាំងពីមន្ត្រីត្រួតពិនិត្យទៅមន្ត្រីសម្ភាសន៍ បញ្ជូនកម្រងសំណួរបុគ្គលទៅសមាជិកក្រុម និងកម្រងសំណួរបំពេញរួចពីមន្ត្រីសម្ភាសន៍ទៅមន្ត្រីត្រួតពិនិត្យ។ ប្រព័ន្ធប្រមូលទិន្នន័យ CAPI ដែលប្រើប្រាស់ក្នុងឆ្នាំ CDHS ២០២១-២២ ត្រូវបានរៀបចំដោយកម្មវិធីអង្កេត DHS ជាមួយនឹងការប្រើប្រាស់ចល័តរបស់កម្មវិធី CSPro ។

## ២.៣ ការវាស់វែងមនុស្សមាត្រ

ការថ្លឹងទម្ងន់ត្រូវបានប្រើជញ្ជីងថ្លឹងម្តាយ និងកូនជាមួយនឹងបង្ហាញលើអេក្រង់ឌីជីថល (UNICEF-លេខម៉ូដែល S0១៨១០២៥)។ ការវាស់កម្ពស់ និងប្រវែងត្រូវបានវាស់ដោយការវាស់វែងដោយប្រើប្រព័ន្ធវាស់កម្ពស់ប្រវែងទារក/មនុស្សពេញវ័យ (UNICEF-លេខម៉ូដែល S0១១៤៥៤០)។ កុមារដែលមានអាយុតិចជាង ២៤ ខែត្រូវវាស់ដេក

(recumbent length) នៅលើបន្ទះក្តារ ហើយកុមារដែលមានអាយុច្រើនជាងត្រូវបានវាស់ឈរ ។ រង្វង់ដើមដៃពាក់ផ្នែកខាងលើ (MUAC) ត្រូវបានវាស់ដោយប្រើកាសែត MUAC បទដ្ឋានថ្មី (UNICEF—លេខម៉ូដែល S០១៤៥៦២០)។

ដើម្បីវាយតម្លៃភាពច្បាស់លាស់នៃការវាស់កម្ពស់ ប្រហែល ១០% នៃកុមារត្រូវបានជ្រើសរើសដោយចៃដន្យ ដើម្បីវាស់ជាលើកទីពីរ។ កម្មវិធី DHS កំណត់ភាពខុសគ្នាតិចជាង ១ សង់ទីម៉ែត្ររវាងការវាស់កម្ពស់ទាំងពីរជាកម្រិតនៃភាពជាក់លាក់ដែលអាចទទួលយកបាន។ កុមារដែលមានពិន្ទុ Z តិចជាង -៣ ឬច្រើនជាង ៣ សម្រាប់កម្ពស់សម្រាប់អាយុ ទម្ងន់សម្រាប់កម្ពស់ ឬទម្ងន់សម្រាប់អាយុត្រូវបានសម្គាល់ និងវាស់វែងជាលើកទីពីរ។ ការវាស់វែងឡើងវិញនៃករណីដែលបានសម្គាល់ត្រូវបានអនុវត្ត ដើម្បីធានាបាននូវស្រង់ត្រឹមត្រូវនៃការវាស់វែងកម្ពស់ និងថ្លឹងទម្ងន់។

## ២.៤ អង្កេតសាកល្បង

អង្កេតសាកល្បងលើកម្រងសំណួរត្រូវបានអនុវត្តមុនពេលចុះប្រតិបត្តការមូលដ្ឋានសម្រាប់អង្កេត CDHS ធ្វើឡើងនៅចន្លោះថ្ងៃទី ២ ដល់ថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ ២០២១។ ការបណ្តុះបណ្តាលកម្រងសំណួរត្រូវមានពីរដំណាក់កាល គឺ២សប្តាហ៍ដំបូងត្រូវបានបែងចែកសម្រាប់ការបណ្តុះបណ្តាលកម្រងសំណួរជាក្រដាស បន្ទាប់មក ៣ ថ្ងៃសម្រាប់ការបណ្តុះបណ្តាល CAPI និង ២ ថ្ងៃសម្រាប់ការអនុវត្តជាក់ស្តែង។ ជំនួយបច្ចេកទេស ICF បានផ្តល់ជូនសម្រាប់ការអនុវត្តជាក់ស្តែងនេះ។

### ២.៤.១ បណ្តុះបណ្តាលមន្ត្រីសម្ភាសន៍

មន្ត្រីចំនួន ៣០ នាក់ត្រូវបានជ្រើសរើសឲ្យចូលរួមក្នុងវគ្គបណ្តុះបណ្តាលកម្រងសំណួរដែលមានបុរស ១៧ នាក់ ស្រី ១៣ នាក់ (មន្ត្រីសម្ភាសន៍ ២០ នាក់ មន្ត្រីត្រួតពិនិត្យ ៥ នាក់ និងអ្នកបច្ចេកទេស មនុស្សមាត្រ ៥ នាក់)។អ្នកសម្របសម្រួលពី NIS ប្រាំនាក់ និងបុគ្គលិក ICF ម្នាក់បានធ្វើការបណ្តុះបណ្តាលលើកម្រងសំណួរ។ ការបណ្តុះបណ្តាលការវាស់កម្ពស់ ថ្លឹងទម្ងន់ វាស់ដើមដៃត្រូវបានធ្វើឡើងដាច់ដោយឡែកពីគ្នាដោយមានក្រុមការងារអ្នកបច្ចេកទេសចំនួន ៥ នាក់ពីអង្គការ UNICEF ។ មន្ត្រីទាំង ៣០ ត្រូវបានរំពឹងថានឹងបានចូលរួមក្នុងការអង្កេតនេះ។

វគ្គបណ្តុះបណ្តាលនេះធ្វើឡើងជាភាសាខ្មែរ។ ការសម្ភាសន៍ក្រុមតូចៗត្រូវបានរៀបចំឡើងនៅចុងបញ្ចប់នៃការបណ្តុះបណ្តាល។ សិក្ខាកាមម្នាក់ៗត្រូវបំពេញកម្រងសំណួរគ្រួសារមួយ និងកម្រងសំណួរបុគ្គលចំនួនពីរ។ ទិន្នន័យដែលប្រមូលបានក្នុងអំឡុងពេលការអនុវត្តលំហាត់ ក្រោយមកត្រូវបានប្រើប្រាស់ក្នុងវគ្គបណ្តុះបណ្តាលដើម្បីសាកល្បងកម្មវិធី CAPI និងដើម្បីអនុវត្តការប្រមូលទិន្នន័យនៅលើថេប្លេត ។ មន្ត្រីសម្របសម្រួលពីក្រសួងសុខាភិបាលបានផ្តល់វគ្គបណ្តុះបណ្តាលលើប្រធានបទសុខភាពផ្សេងៗ រួមមាន ផែនការគ្រួសារ និងសុខភាពបន្តពូជ មេរោគអេដស៍/ជំងឺអេដស៍ អាហារូបត្ថម្ភ និងការចាក់វ៉ាក់សាំងកុមារ។

ការបណ្តុះបណ្តាលគ្រូបង្គោល (TOT) សម្រាប់ CAPI ត្រូវបានធ្វើឡើងនៅថ្ងៃទី ១៦ដល់ថ្ងៃ២៤ ខែមិថុនា ឆ្នាំ

២០២១ សម្រាប់មន្ត្រីបង្គោលរបស់ NIS ចំនួន ៥ នាក់ ហើយវគ្គបណ្តុះបណ្តាល CAPI អង្កេតសាកល្បងបាន ធ្វើឡើងចាប់ពីថ្ងៃទី ២៣-២៥ ខែមិថុនា ឆ្នាំ ២០២១ ដែលមានមន្ត្រីចូលរួមចំនួន ៣០ នាក់ រួមទាំងអ្នក បច្ចេកទេសមនុស្សមាត្រ( biomarker) ផងដែរ។
មន្ត្រីសម្ភាសន៍ និងអ្នកបច្ចេកទេសមនុស្សមាត្របានធ្វើការអនុវត្តការងាររយៈពេល ២ ថ្ងៃ ដើម្បីពង្រឹងជំនាញ ដែលបានរៀនកំឡុងពេលបណ្តុះបណ្តាល និងដើម្បីទទួលនូវបទពិសោធន៍ការងារដើម្បីធ្វើតេស្តសាកល្បង លើសម្ភារៈអង្កេត។ មន្ត្រីចូលរួមអង្កេតសាកល្បងបែងជា ៥ ក្រុមដែលដើម្បីអនុវត្តន៍ការងារជាក់ស្តែង (មន្ត្រី ត្រួតពិនិត្យ ១ នាក់ មន្ត្រីសម្ភាសន៍ ៤ នាក់ និងអ្នកបច្ចេកទេសមនុស្សមាត្រ ១ នាក់) ។ ការអនុវត្ត នេះបានធ្វើនៅ ភូមិចំនួន ៥ ក្នុងខេត្តកំពង់ធំ។ គ្រួសារចំនួន ២៤ ត្រូវបានជ្រើសរើសនៅក្នុងភូមិនីមួយៗសម្រាប់ក្រុមដើម្បី ប្រមូលទិន្នន័យក្នុងអំឡុងពេលអនុវត្តសាកល្បងនេះ។ ជារួមគ្រួសារចំនួន ៧៨ ស្ត្រីគោលដៅ ៥៨ នាក់ និង បុរសគោលដៅ ៦១ នាក់ ត្រូវបានសម្ភាសន៍។

## ២.៥ បណ្តុះបណ្តាលមន្ត្រីមូលដ្ឋាន

### ២.៥.១ ការបណ្តុះបណ្តាលកម្រងសំណួរ

ការបណ្តុះបណ្តាលចម្បងសម្រាប់អង្កេត CDHS ឆ្នាំ២០២១-២២ ត្រូវបានរៀបចំឡើងនៅសាលប្រជុំធំរបស់ ក្រសួងផែនការក្នុងរាជធានីភ្នំពេញ។ មន្ត្រីមួយរយម្ភៃប្រាំនាក់បានចូលរួមក្នុងវគ្គបណ្តុះ បណ្តាលនេះ (មន្ត្រី សម្ភាសន៍ ១០០ នាក់ និងត្រួតពិនិត្យ ២៥ នាក់)។ ចាប់ពីថ្ងៃទី ១៩ ខែកក្កដា ដល់ថ្ងៃទី ៣១ ខែកក្កដា មន្ត្រី ទាំងអស់បានចូលរួមក្នុងវគ្គបណ្តុះបណ្តាលកម្រងសំណួរ។ មន្ត្រីសម្របសម្រួលវិទ្យាស្ថានជាតិស្ថិតិ (NIS) ចំនួនពីរនាក់ និងអ្នកបច្ចេកទេសពី ICF ម្នាក់បានធ្វើការ បណ្តុះបណ្តាលលើកម្រងសំណួរ។ មន្ត្រីចូលរួម ប្រហែលជាងពាក់កណ្តាលប៉ុណ្ណោះដែលធ្លាប់បានចូលរួមក្នុងអង្កេត CDHS លើកមុនៗ ឬអង្កេតផ្សេងទៀតខ ណៈដែលមន្ត្រីផ្សេងទៀតមិនមានបទពិសោធន៍ក្នុងការអង្កេត ។ ៤០ ភាគរយ (៥០) នៃមន្ត្រីចូលរួមទាំងនេះ មកពីមន្ទីរសុខាភិបាលរាជធានី ខេត្ត ៤០ ភាគរយ (៥០) ទៀតមកពីមន្ទីរផែនការរាជធានី ខេត្ត និង ២០ ភាគរយ (២៥) មកពីវិទ្យាស្ថានជាតិស្ថិតិ (NIS) ។

ការសម្ភាសន៍ជាក្រុមតូចៗត្រូវបានរៀបចំឡើងនៅចុងបញ្ចប់នៃវគ្គបណ្តុះបណ្តាល។ សិក្ខាកាមម្នាក់ៗតម្រូវឱ្យ បំពេញកម្រងសំណួរគ្រួសារមួយ និងកម្រងសំណួរបុគ្គលចំនួនពីរ។ ទិន្នន័យដែលប្រមូលបានក្នុងអំឡុងពេល លំហាត់អនុវត្ត ក្រោយមកត្រូវបានប្រើប្រាស់ក្នុងវគ្គបណ្តុះបណ្តាលដើម្បីសាកល្បងកម្មវិធី CAPI និងដើម្បីអនុ វត្តការប្រមូលទិន្នន័យនៅលើថេប្លេត ។ តំណាងមកពីដៃគូអភិវឌ្ឍន៍ នាយកដ្ឋានពាក់ព័ន្ធនៃក្រសួងសុខាភិបា ល និងកិច្ចការនារីបានចូលរួមវគ្គបណ្តុះបណ្តាលតាមរយៈវីដេអូពីចម្ងាយ (Zoom) ។ មន្ត្រីទាំងនោះបានចូល រួមតាមអ៊ីនធឺណិតដើម្បីពិភាក្សាលើប្រធានបទទាក់ទងនឹងសុខភាពកុមារ និងការអភិវឌ្ឍន៍កុមារតូច ផែនការ គ្រួសារ និងសុខភាពបន្តពូជ មេរោគអេដស៍/ជំងឺអេដស៍ អាហារូបត្ថម្ភ ការចាក់ថ្នាំបង្ការ និងអំពើហិង្សាក្នុង គ្រួសារជាដើម។
បញ្ញាប្រឈមធំៗសម្រាប់ការអង្កេតនេះ មន្ត្រីចូលរួមវគ្គបណ្តុះបណ្តាលត្រូវបានជ្រើសរើសដោយ MOH និង NIS ក្រសួងផែនការពីមន្ទីររាជធានី ខេត្តរៀងខ្លួន។ មន្ត្រីចូលរួមភាគច្រើនបានបំពេញ លក្ខណៈសម្បត្តិដូចការ

រំពឹងទុក រួមទាំងបទពិសោធន៍ក្នុងការប្រើប្រាស់កុំព្យូទ័រ និងធ្លាប់បានចូលរួមការងារអង្កេតណាមួយពីមុនមក ។ ការជ្រើសរើសមន្ត្រីត្រូវបានធ្វើឡើងសម្រាប់តែតម្រូវការក្នុងអង្កេតប៉ុណ្ណោះ ដោយមិនមានមន្ត្រីបម្រុងត្រូវបានបណ្តុះបណ្តាលបន្ថែមឡើយ ដូច្នេះការជ្រើសរើសឡើងវិញមិនត្រូវបានធ្វើសម្រាប់អង្កេតនេះ ។

### ២.៥.២ការបណ្តុះបណ្តាលមនុស្សមាត្រ

វគ្គបណ្តុះបណ្តាលផ្នែកមនុស្សមាត្រនេះ ធ្វើឡើងដោយអ្នកជំនាញអាហារូបត្ថម្ភពីក្រសួងសុខាភិបាល (MOH)។ ដោយសារគោលនយោបាយកាត់បន្ថយហានិភ័យនៃជំងឺកូវីដ-១៩ របស់អង្គការ UNICEF មិនអាចចូលរួមដោយផ្ទាល់បានទេគឺត្រូវចូលរួមតាមរយៈវីដេអូពីចម្ងាយ (Zoom)។ ទោះជាយ៉ាងណាក៏ដោយ ដោយសារតែមានការរឹតបន្តឹងលើ COVID-១៩ ស្ត្រី និងកុមារដែលតម្រូវឱ្យអនុវត្តសម្រាប់មនុស្សមាត្រ និងបទដ្ឋានជាក់ស្តែងក្នុងពេលបណ្តុះបណ្តាលមិនត្រូវបានអនុញ្ញាតឱ្យចូលមកក្នុងអគារ NIS ឡើយ ។ ដូចគ្នានេះផងដែរសម្រាប់ហេតុផលដូចគ្នានេះដែរការប្រជុំ ឬការជួបជុំគ្នានៅមូលដ្ឋានក៏មិនអាចអនុវត្តន៍ទៅបានសម្រាប់ការអនុវត្តជាក់ស្តែងមនុស្សមាត្រ និងបទដ្ឋានអំឡុងពេលបណ្តុះបណ្តាល។ ការអនុវត្តលើការវាស់ស្ទង់មនុស្សពេញវ័យត្រូវបានធ្វើឡើងក្នុងចំណោមមន្ត្រីសម្ភាសន៍ និងមន្ត្រី NIS ដែលស្ម័គ្រចិត្ត ។

### ២.៥.៣ ការបណ្តុះបណ្តាល CAPI

ការបណ្តុះបណ្តាល CAPI ត្រូវបានធ្វើឡើងចាប់ថ្ងៃទី ២ ដល់ថ្ងៃទី ២១ ខែសីហា ជាមួយនឹងជំនួយការបច្ចេកទេសដោយផ្ទាល់ និងពីចម្ងាយ (Zoom) ។ ការបណ្តុះបណ្តាល CAPI ធ្វើឡើងមានរយៈពេលយូរជាងធម្មតាដោយសារតែវិបត្តិ COVID-១៩ បានកើតឡើងនៅក្នុងនាយកដ្ឋានព័ត៌មានវិទ្យានៅចុងសប្តាហ៍ដំបូង។ ការជួបជុំធំមិនត្រូវបានអនុញ្ញាតជាហេតុតម្រូវឲ្យមន្ត្រីដែលចូលរួមវគ្គបណ្តុះបណ្តាលត្រូវបានបំបែកជាបួនក្រុមតូចៗ។ ពីរក្រុមត្រូវបានបណ្តុះបណ្តាលក្នុងមួយថ្ងៃ មួយក្រុមពេលព្រឹកចាប់ពីម៉ោង ៨:០០ ព្រឹកដល់ម៉ោង ១២:៣០ ថ្ងៃត្រង់ និងមួយក្រុមទៀតនៅពេលព្រឹកចាប់ពីម៉ោង ១:៣០ រសៀលដល់ម៉ោង ៥:៣០ រសៀល។ ត្រូវចំណាយពេល ២ ថ្ងៃដើម្បីបង្ហាញប្រធានបទដែលនៅសល់នីមួយៗនៅលើរបៀបវារៈ។ ប្រព័ន្ធ CAPI ត្រូវបានបកប្រែជាភាសាខ្មែរ រួមមានសំណួរ ប្រភេទនៃការឆ្លើយតប សារបង្ហាញកំហុស ជម្រើសផ្សេងៗ ។ល។ ការបកប្រែ និងការត្រួតពិនិត្យទាំងនេះធ្វើឡើងដោយ ICF និងមន្ត្រីបង្គោលពី NIS ។ កម្រងសំណួររបស់គ្រួសារ ស្ត្រី បុរស និងមនុសមាត្រ ក៏ដូចជាប្រព័ន្ធ CAPI របស់មន្ត្រីសម្ភាសន៍ និងមន្ត្រីត្រួតពិនិត្យក៏ត្រូវបានបកប្រែជាភាសាខ្មែរផងដែរ។

មន្ត្រីដែលចូលរួមវគ្គបណ្តុះបណ្តាលត្រូវបានបែងចែកជា ២៥ ក្រុម ដែលក្រុមនីមួយៗមានមន្ត្រីត្រួតពិនិត្យម្នាក់ និងមន្ត្រីសម្ភាសន៍ ៤ នាក់ដែលពួកគេនឹងត្រូវទៅខេត្តជាមួយគ្នា។ ក្នុងអំឡុងពេលបណ្តុះបណ្តាលមន្ត្រីចូលរួមបានរៀនពីរបៀបកត់ត្រាការឆ្លើយតបនៅក្នុងប្រព័ន្ធ CAPI និងប្រើប៊្លូធូត (Bluetooth) ដើម្បីផ្លាស់ប្តូរកិច្ចការ និងផ្ទេរទិន្នន័យកម្រងសំណួរ និងការបច្ចុប្បន្នភាពក្នុងប្រព័ន្ធ CAPI ។ មន្ត្រីត្រួតពិនិត្យក៏ត្រូវរៀនពីរបៀបប្រើប្រាស់ការតភ្ជាប់អ៊ីធឺណិត និងប្រព័ន្ធបញ្ជូនឯកសារតាមអ៊ីនធឺណិត (IFSS) ដើម្បីផ្ញើទិន្នន័យមកកាន់ការិយាល័យកណ្តាល និងរក្សាឯកសារក្នុងប្រព័ន្ធ CAPI នៅក្នុងថេប្លេតរផងដែរ។

ដោយសារការរឹតបន្តឹង និងបទប្បញ្ញត្តិនៃកូវីដ-១៩ ការអនុវត្តជាក់ស្តែងមិនអាចត្រូវបានអនុវត្តនៅក្នុងភូមិបានទេ បន្ទាប់ពីវគ្គបណ្តុះបណ្តាលបានបញ្ចប់។ ផ្ទុយទៅវិញមន្រ្តីសម្ភាសន៍ត្រូវបានស្នើឱ្យប្រមូលទិន្នន័យនៅផ្ទះ និងក្នុងសង្កាត់របស់ពួកគេស្នាក់នៅ។ នេះបានធ្វើឱ្យសិក្ខាកាមបញ្ចប់កម្មវិធីសិក្សាបណ្តុះបណ្តាល និងទទួលបានបទពិសោធន៍អំពីរបៀបប្រើប្រាស់ប្រព័ន្ធ CAPI សម្រាប់ការប្រមូលទិន្នន័យ រួមទាំងការបិទបញ្ចប់សម្ភាសន៍ក្នុងមណ្ឌលអង្កេតផងដែរ។ មណ្ឌលអង្កេតត្រូវបានបង្កើតឡើងសម្រាប់បែងចែកក្រុមនិមួយៗ ហើយមណ្ឌលអង្កេតនីមួយៗមានចំនួន ៥ គ្រួសារ។ មន្រ្តីសម្ភាសន៍តាមក្រុមនីមួយៗ និងត្រួតពិនិត្យបានសម្ភាសន៍យ៉ាងហោចណាស់មួយគ្រួសារដោយប្រើកម្រងសំណួរគ្រួសារ និងមនុស្សពេញវ័យដែលស្ថិតក្នុងគោលដៅទាំងអស់ដែលមានភេទដូចគ្នាជាមួយអ្នកសម្ភាសន៍ (ដោយប្រើកម្រងសំណួរបុគ្គលដែលស្រប) ។ កម្រងសំណួរមនុស្សមាត្រក៏ត្រូវបានបញ្ចប់ និងបញ្ចូលក្នុងប្រព័ន្ធ CAPI ផងដែរ។ ការអនុវត្តបែបនេះជាទូទៅនឹងមិនជំនួសការអនុវត្តនៅមូលដ្ឋានជាក់ស្តែងនោះទេ។ តែទោះជាយ៉ាងណាក៏ដោយនៅក្នុងកាលៈទេសៈនេះពិតជាមានប្រយោជន៍ណាស់ក្នុងការបញ្ចប់វគ្គបណ្តុះបណ្តាលដោយជោគជ័យ។ ដើម្បីជានាចំណុចសំខាន់បំផុតមួយនៃវគ្គបណ្តុះបណ្តាលត្រូវបានសម្រេចដោយជោគជ័យ។

## ២.៦ ប្រតិបត្តិការមូលដ្ឋាន

ការស្រង់ទិន្នន័យត្រូវបានអនុវត្តដោយក្រុមចំនួន ២៥ ។ ក្រុមនីមួយៗត្រូវបានផ្តល់ជូនរថយន្តជាមួយអ្នកបើកបរ។ មន្រ្តីសម្របសម្រួលពី NIS និង MOH បានសម្របសម្រួល និងត្រួតពិនិត្យសកម្មភាពការងារមូលដ្ឋានយ៉ាងជិតដល់។ ICF បានផ្តល់ជំនួយបច្ចេកទេសពីចម្ងាយក្នុងអំឡុងពេលស្រង់ទិន្នន័យទាំងមូល។ ការងារមូលដ្ឋានចាប់ផ្តើមនៅថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ ២០២១ នៅទូទាំង ២៥ រាជធានី ខេត្ត ដោយក្រុមនីមួយៗទទួលខុសត្រូវតែមួយខេត្ត។ ក្រុមនិមួយៗត្រូវបានត្រួតពិនិត្យយ៉ាងជិតដល់ដោយ មន្រ្តីសម្របសម្រួលមូលដ្ឋានទាំងប្រាំសម្រាប់ការត្រួតពិនិត្យគុណភាព អង្កេត។ មានករណីជាច្រើនដែលក្រុមត្រូវផ្លាស់ប្តូរទិសដៅដែលបានគ្រោងទុក ឬផ្អាកសកម្មភាពនៅតាមគោលដៅដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ នៅក្នុងខេត្តរបស់ពួកគេចុះប្រតិបត្តិការ។ ការស្រង់ទិន្នន័យត្រូវបានបញ្ចប់ដោយជោគជ័យនៅថ្ងៃទី ១៥ ខែកុម្ភៈ ឆ្នាំ ២០២២។

ការត្រួតពិនិត្យការងារមូលដ្ឋានគឺជាផ្នែកសំខាន់មួយនៃអង្កេត CDHS ឆ្នាំ ២០២១-២២ ហើយត្រូវបានអនុវត្តដោយមន្រ្តីពី NIS, MOH និង ICF (ពីចម្ងាយ) កំឡុងពេលស្រង់ទិន្នន័យនៅមូលដ្ឋាន។ មន្រ្តីសម្របសម្រួល NIS និង MOH ត្រូវបានបំពាក់បំប៉នយ៉ាងស្ទាត់ជំនាញសម្រាប់ការណែនាំត្រួតពិនិត្យ។ រៀងរាល់សប្តាហ៍មន្រ្តីពី NIS និង ICF បានបង្កើតតារាងត្រួតពិនិត្យមូលដ្ឋានទិន្នន័យសម្ភាសន៍ដែលបានបញ្ចប់ ដើម្បីតាមដានវឌ្ឍនភាពការងារ និងគុណភាពទិន្នន័យ។ ការកែលម្អត្រូវបានផ្តល់ជូនយ៉ាងទៀងទាត់ដោយមន្រ្តីសម្របសម្រួល និងមន្រ្តីត្រួតពិនិត្យ និងសម្ភាសន៍។

## ២.៧ ការកែច្នៃទិន្នន័យ

ការកែច្នៃទិន្នន័យអង្កេត CDHS ឆ្នាំ២០២១-២២ បានចាប់ផ្តើមភ្លាមៗអំឡុងពេលការងារស្រង់ទិន្នន័យចាប់ផ្តើម។ អំឡុងពេលស្រង់ទិន្នន័យត្រូវបានបញ្ចប់ក្នុងមណ្ឌលអង្កេតនីមួយៗទិន្នន័យជាអេឡិចត្រូនិចទាំងអស់ត្រូវបានផ្ទេរតាមរយៈប្រព័ន្ធអ៊ីនធឺណេត (IFSS) មកការិយាល័យកណ្តាល NIS ក្នុងរាជធានីភ្នំពេញ។ ទិន្នន័យទាំងនេះត្រូវបានកត់ត្រា និងពិនិត្យមើលភាពមិនស៊ីគ្នា ភាពមិនពេញលេញដែលបំពេញគ្រប់ជ្រុងជ្រោយ។ ទិន្នន័យមិនស៊ីគ្នា និងកំហុសដែលរកឃើញត្រូវបានទាក់ទងជាមួយមន្ត្រីតាមក្រុមនិមួយៗដើម្បីពិនិត្យ និងកែតម្រូវឡើងវិញ។ ការសម្អាតទិន្នន័យត្រូវបានអនុវត្តនៅការិយាល័យកណ្តាលរួមបញ្ចូលការដោះស្រាយភាពមិនស៊ីគ្នា និងការសរសេរកូដសម្រាប់សំណួរបើក ។ ការសម្អាតទិន្នន័យត្រូវបានធ្វើឡើងដោយប្រព័ន្ធកែច្នៃទិន្នន័យ NIS ។ កម្រងសំណួរមនុស្សមាត្រជាក្រដាសត្រូវបានប្រមូលដោយមន្ត្រីសម្របសម្រួលដើម្បីប្រៀបធៀបជាមួយទិន្នន័យអេឡិចត្រូនិកពិនិត្យភាពមិនស៊ីគ្នាណាមួយក្នុងអំឡុងពេលបញ្ចូលទិន្នន័យ។ ការកែច្នៃទិន្នន័យត្រូវបានអនុវត្តដោយប្រើកម្មវិធី CSPro ។ ការសម្អាតទិន្នន័យទិន្នន័យក្នុងពេលដំណាលគ្នាបានផ្តល់នូវប្រយោជន៍ដើម្បីសំអាតទិន្នន័យដែលគ្មានកំហុសជាអតិបរមា និងត្រឹមត្រូវ។ ការទាញតារាងត្រួតពិនិត្យទិន្នន័យទាន់ពេលវេលាធានាបានការត្រួតពិនិត្យប្រកបដោយប្រសិទ្ធភាព។ ការកែច្នៃលើកទីពីរនៃទិន្នន័យត្រូវបានបញ្ចប់នៅក្នុងខែមីនា ឆ្នាំ ២០២២។

របាយការណ៍នេះបង្ហាញលេខក្នុងតារាងដែលត្រូវបានទាញដោយភ្ជាប់នឹងមេគុណសំណាកគំរូ (weighted )។ តួលេខប្រមាណជា ២៥ ទៅ ៤៩ ភាគរយ មិនបានភ្ជាប់នឹងមេគុណសំណាកគំរូឡើយត្រូវបានបង្ហាញក្នុងវង់ក្រចក ហើយភាគរយដែលតួលេខមានករណីតិចជាង ២៥ មិនត្រូវបានភ្ជាប់នឹងមេគុណសំណាកគំរូ និងជំនួសដោយសញ្ញាផ្កាយ ដើម្បីបង្ហាញអ្នកអាននៅពេលបកស្រាយទិន្នន័យថាភាគរយដែលមានករណីតិចជាង ៥០ អាចមិនជឿជាក់បានឡើយ។

# លទ្ធផលបឋម ៣

## ៣.១ អត្រាឆ្លើយតប

អង្កេត CDHS ២០២១-២២ តារាង ១ បង្ហាញពីទំហំសំណាកគំរូ និងអត្រាឆ្លើយតប។ សំណាកគំរូគ្រួសារសរុបចំនួន ២១.២៧០ ដែលបានជ្រើសរើសត្រូវបានរកឃើញ ២០.៩៦៧ គ្រួសារនិងត្រូវបានសម្ភាសន៍ប្រកបដោគជ័យចំនួន ២០.៨០៦ គ្រួសារក្នុងអត្រាឆ្លើយតបស្មើ ៩៩%។ ក្នុងចំណោមគ្រួសារដែលបានសម្ភាសន៍ទាំងនេះស្ត្រីចំនួន ១៩.៨៤៥ នាក់ដែលមានអាយុ ១៥-៤៩ ឆ្នាំត្រូវបានកំណត់ជាក្រុមគោលដៅក្នុងការសម្ភាសហើយស្ត្រី ១៩.៤៩៦ នាក់ត្រូវបានសម្ភាសន៍បញ្ចប់ពេញលេញស្មើនឹង ៩៨% ។ ក្នុងចំណោមបុរសគោលដៅសម្ភាសន៍ចំនួន ៩.០៧៩ នាក់អាយុ ១៥-៤៩ ឆ្នាំដែលកំណត់ជាក្រុមគោលដៅក្នុងការសម្ភាសមាន ៨.៨២៥ នាក់ត្រូវបានសម្ភាសន៍ប្រកបដោយជោគជ័យក្នុងអត្រាឆ្លើយតបស្មើ ៩៧%។

តារាង ១ លទ្ធផលនៃការសម្ភាសន៍គ្រួសារ និងបុគ្គល

ចំនួនគ្រួសារ ចំនួនសម្ភាសន៍ និងអត្រាឆ្លើយតបតាមតំបន់ (គ្មានមេគុណគំរូ) កម្ពុជា DHS ២០២១-២២

| លទ្ធផល | តំបន់: ទីប្រជុំជន | តំបន់: ជនបទ | សរុប |
|---|---|---|---|
| គ្រួសារសម្ភាសន៍ | | | |
| ចំនួនគ្រួសារជ្រើសរើស | 7,230 | 14,040 | 21,270 |
| ចំនួនគ្រួសាររកឃើញ | 7,127 | 13,840 | 20,967 |
| ចំនួនគ្រួសារសម្ភាសន៍ | 7,059 | 13,747 | 20,806 |
| អត្រាគ្រួសារឆ្លើយតប [1] | 99.0 | 99.3 | 99.2 |
| ស្ត្រីសម្ភាសន៍អាយុ ១៥-៤៩ | | | |
| ចំនួនស្ត្រីជ្រើសរើស | 7,163 | 12,682 | 19,845 |
| ចំនួនស្ត្រីសម្ភាសន៍ | 7,033 | 12,463 | 19,496 |
| អត្រាស្ត្រីឆ្លើយតប [2] | 98.2 | 98.3 | 98.2 |
| គ្រួសារសម្ភាសន៍សំណាកគំរូរង | | | |
| ចំនួនគ្រួសារជ្រើសរើស | 3,615 | 7,020 | 10,635 |
| ចំនួនគ្រួសាររកឃើញ | 3,563 | 6,903 | 10,466 |
| ចំនួនគ្រួសារសម្ភាសន៍ | 3,531 | 6,856 | 10,387 |
| អត្រាឆ្លើយតបសំណាកគំរូរង | 99.1 | 99.3 | 99.2 |
| បុរសសម្ភាសន៍អាយុ ១៥-៤៩ | | | |
| ចំនួនបុរសជ្រើសរើស | 3,237 | 5,842 | 9,079 |
| ចំនួនបុរសសម្ភាសន៍ | 3,166 | 5,659 | 8,825 |
| អត្រាបុរសឆ្លើយតប [2] | 97.8 | 96.9 | 97.2 |

[1] *ចំនួនគ្រួសារដែលបានសម្ភាសន៍/ គ្រួសារដែលបានរកឃើញ.*

[2] *ចំនួនអ្នកផ្តល់ចម្លើយ/ចំនួនអ្នកផ្តល់ចម្លើយគោលដៅសម្ភាសន៍.*

## ៣.២ ចរិតលក្ខណៈអ្នកផ្តល់ចម្លើយ

តារាង ២ បង្ហាញពីការបែងចែកស្ត្រី និងបុរសមានអាយុ ១៥-៤៩ ឆ្នាំ ភ្ជាប់នឹងមេគុណអង្កេត និងគ្មានមេគុណអង្កេតដែលបានសម្លាសន៍ក្នុងតាមចរិតលក្ខណៈអង្កេត CDHS ២០២១–២២ ។ លទ្ធផលបង្ហាញក្នុងរបាយការណ៍នេះផ្អែកលើមេគុណអង្កេតដែលតំណាងឲ្យថ្នាក់ជាតិ ទីប្រជុំជន និងជនបទ និងតាមរាជធានី ខេត្តនិមួយៗ ។

តារាង ២ ចរិតលក្ខណៈនៃអ្នកផ្តល់ចម្លើយ

ភាគរយស្ត្រី និងបុរសអាយុ ១៥-៤៩ តាមចរិតលក្ខណៈអង្កេត កម្ពុជា ២០២១-២២

| ចរិតលក្ខណៈអង្កេត | ស្ត្រី | | | បុរស | | |
|---|---|---|---|---|---|---|
| | មេគុណ ភាគរយ | មេគុណ ចំនួន | មេគុណ ភាគរយ | មេគុណ ចំនួន | មេគុណ ភាគរយ | មេគុណ ចំនួន |
| **អាយុ** | | | | | | |
| 15-19 | 15.3 | 2,981 | 3,099 | 17.7 | 1,559 | 1,543 |
| 20-24 | 13.3 | 2,589 | 2,684 | 13.9 | 1,226 | 1,223 |
| 25-29 | 15.3 | 2,986 | 3,052 | 14.7 | 1,299 | 1,309 |
| 30-34 | 16.8 | 3,272 | 3,192 | 16.2 | 1,432 | 1,408 |
| 35-39 | 17.3 | 3,367 | 3,241 | 16.0 | 1,416 | 1,440 |
| 40-44 | 13.3 | 2,598 | 2,557 | 13.5 | 1,191 | 1,194 |
| 45-49 | 8.7 | 1,704 | 1,671 | 8.0 | 702 | 708 |
| **រាយការណ៍អំពីស្ថានភាពសុខភាព** | | | | | | |
| ល្អណាស់ | 3.6 | 709 | 845 | 8.9 | 786 | 624 |
| ល្អ | 68.3 | 13,307 | 12,876 | 64.2 | 5,664 | 5,411 |
| ធម្មតា | 25.5 | 4,971 | 5,255 | 24.7 | 2,184 | 2,614 |
| អាក្រក់ | 2.5 | 494 | 504 | 2.1 | 187 | 171 |
| អាក្រក់ណាស់ | 0.1 | 15 | 16 | 0.0 | 4 | 5 |
| **សាសនា** | | | | | | |
| ព្រះពុទ្ធ | 97.4 | 18,980 | 18,846 | 97.3 | 8,590 | 8,570 |
| មូស្លីម | 1.8 | 342 | 415 | 2.1 | 183 | 191 |
| គ្រិះស្ទាន | 0.7 | 135 | 190 | 0.5 | 47 | 59 |
| គ្មានសាសនា | 0.2 | 38 | 43 | 0.1 | 5 | 5 |
| ផ្សេងទៀត | 0.0 | 2 | 2 | 0.0 | 0 | 0 |
| **ស្ថានភាពអាពាហ៍ពិពាហ៍** | | | | | | |
| នៅលីវឬមិនដែលរៀបការ | 24.6 | 4,788 | 4,616 | 34.9 | 3,078 | 2,918 |
| រៀបការ | 68.1 | 13,269 | 13,513 | 61.3 | 5,407 | 5,607 |
| រស់នៅជាមួយគ្នា | 1.1 | 223 | 242 | 1.0 | 90 | 75 |
| លែងលះ/រស់នៅផ្សេងគ្នា | 4.2 | 815 | 719 | 2.5 | 219 | 183 |
| មេម៉ាយ/ពោះម៉ាយ | 2.1 | 400 | 406 | 0.3 | 31 | 42 |
| **តំបន់** | | | | | | |
| ទីប្រជុំជន | 42.3 | 8,239 | 7,033 | 42.6 | 3,762 | 3,166 |
| ជនបទ | 57.7 | 11,257 | 12,463 | 57.4 | 5,063 | 5,659 |
| **រាជធានី ខេត្ត** | | | | | | |

| | | | | | | |
|---|---|---|---|---|---|---|
| បន្ទាយមានជ័យ | 3.9 | 763 | 686 | 3.7 | 327 | 309 |
| បាត់ដំបង | 6.9 | 1,347 | 845 | 7.2 | 636 | 412 |
| កំពង់ចាម | 6.0 | 1,163 | 743 | 6.0 | 533 | 343 |
| កំពង់ឆ្នាំង | 3.5 | 675 | 769 | 2.9 | 259 | 306 |
| កំពង់ស្ពឺ | 6.3 | 1,226 | 890 | 6.0 | 532 | 394 |
| កំពង់ធំ | 4.2 | 819 | 770 | 4.3 | 376 | 338 |
| កំពត | 4.0 | 781 | 805 | 3.6 | 322 | 339 |
| កណ្តាល | 7.4 | 1,445 | 887 | 7.7 | 678 | 419 |
| កោះកុង | 0.7 | 140 | 681 | 0.7 | 60 | 309 |
| ក្រចេះ | 2.3 | 443 | 670 | 2.5 | 216 | 337 |
| មណ្ឌលគីរី | 0.6 | 115 | 827 | 0.6 | 50 | 332 |
| ភ្នំពេញ | 16.2 | 3,160 | 1,073 | 16.9 | 1,490 | 513 |
| ព្រះវិហារ | 1.7 | 332 | 846 | 1.7 | 149 | 382 |
| ព្រៃវែង | 6.3 | 1,233 | 848 | 7.0 | 615 | 436 |
| ពោធិសាត់ | 2.2 | 432 | 504 | 2.5 | 219 | 259 |
| រតនគីរី | 1.5 | 293 | 730 | 1.7 | 149 | 372 |
| សៀមរាប | 7.9 | 1,548 | 898 | 8.5 | 749 | 408 |
| ព្រះសីហនុ | 1.2 | 243 | 701 | 1.3 | 113 | 325 |
| ស្ទឹងត្រែង | 1.0 | 195 | 809 | 0.9 | 81 | 333 |
| ស្វាយរៀង | 3.8 | 735 | 784 | 3.5 | 311 | 337 |
| តាកែវ | 6.0 | 1,162 | 866 | 5.1 | 453 | 345 |
| ឧត្តរមានជ័យ | 1.2 | 242 | 712 | 1.2 | 109 | 333 |
| កែប | 0.3 | 57 | 746 | 0.3 | 26 | 346 |
| ប៉ៃលិន | 0.5 | 96 | 656 | 0.5 | 41 | 302 |
| ត្បូងឃ្មុំ | 4.4 | 851 | 750 | 3.7 | 331 | 296 |
| កម្រិតសិក្សាអប់រំ | | | | | | |
| មិនបានចូលសាលា | 11.6 | 2,265 | 2,762 | 5.8 | 514 | 681 |
| បឋមសិក្សា | 38.7 | 7,554 | 7,773 | 36.5 | 3,220 | 3,450 |
| មធ្យមសិក្សា | 42.5 | 8,278 | 7,846 | 48.4 | 4,273 | 4,044 |
| ខ្ពស់ជាងមធ្យមសិក្សា | 7.2 | 1,399 | 1,115 | 9.3 | 819 | 650 |
| បញ្ចភាគទ្រព្យសម្បត្តិ | | | | | | |
| ទាបបំផុត | 17.4 | 3,400 | 4,927 | 18.2 | 1,607 | 2,299 |
| ទាប | 18.1 | 3,534 | 3,541 | 17.9 | 1,578 | 1,614 |
| មធ្យម | 19.6 | 3,813 | 3,803 | 19.0 | 1,680 | 1,685 |
| ខ្ពស់ | 21.9 | 4,267 | 3,974 | 22.0 | 1,945 | 1,810 |
| ខ្ពស់បំផុត | 23.0 | 4,483 | 3,251 | 22.8 | 2,015 | 1,417 |
| សរុប15-49 | 100.0 | 19,496 | 19,496 | 100.0 | 8,825 | 8,825 |

កំណត់សម្គាល់: ចំណាត់ថ្នាក់អប់រំផ្អែកលើកម្រិតខ្ពស់បំផុតដែលបានសិក្សា មិនសំដៅលើបានបញ្ចប់ឬមិនបានបញ្ចប់នោះទេ

- ភាគរយស្ត្រី និងបុរសអាយុពី ៤៥ ទៅ ៤៩ ឆ្នាំ ( ៩% និង ៨% រៀងគ្នា ) គឺតិចជាងក្រុមអាយុដទៃទៀតដែលឆ្លុះបញ្ចាំងពីរចនាសម្ព័ន្ធអាយុប្រជាជនកម្ពុជានៅក្មេងនៅឡើយ។
- ទាំងស្ត្រី និងបុរសស្ទើរតែ ( ៩៧% ) កាន់សាសនាព្រះពុទ្ធ ។
- ស្ត្រី ៧២% និងបុរស៧៣% បានរាយការណ៍ថាស្ថានភាពសុខភាពពួកគេល្អ ឬល្អណាស់។ មាន ស្ត្រី ៣% និងបុរស ២% បានរាយការណ៍ថាស្ថានភាពសុខភាពរបស់ពួកគេអាក្រក់ ឬអាក្រក់ណាស់។
- ស្ត្រីម្នាក់ក្នុងចំណោម ៤ នាក់ (២៥%) និងបុរសជាង ១ នាក់ក្នុងចំណោម ៣ នាក់ (៣៥%) មិនដែលបានរៀបការ។ ភាគច្រើននៃស្ត្រី (៦៨%) និងបុរស (៦១%) បច្ចុប្បន្នបានរៀបការ។ ស្ត្រី និងបុរស ១% បច្ចុប្បន្នកំពុងរស់នៅជាមួយនរណាម្នាក់ដូចប្ដីប្រពន្ធ ។ ប្រមាណជា ៤% នៃអ្នកឆ្លើយតបស្ត្រី និង៣% នៃអ្នកឆ្លើយតបបុរសបានលែងលះ/រស់នៅផ្សេងគ្នា ។
- ស្ត្រី និងបុរសចំនួន ៦ នាក់ក្នុងចំណោម ១០ នាក់ ( ៥៨% និង ៥៧% តាមលំដាប់រៀង ) រស់នៅជនបទ។
- នៅកម្រិតរាជធានី ខេត្តភាគរយខ្ពស់បំផុតនៃអ្នកឆ្លើយតបស្ត្រី និងបុរស ( ១៦% និង ១៧% តាមលំដាប់រៀង ) គឺនៅរាជធានីភ្នំពេញ។ តិចជាង ១% នៃអ្នកឆ្លើយតបសំណួរស្ថិតនៅក្នុងខេត្តមណ្ឌលគិរី កែប ប៉ៃលិន និងកោះកុង។
- ៥០% នៃស្ត្រី និង ៥៨% នៃបុរសបានធ្លាប់ចូលរៀននៅកម្រិតមធ្យមសិក្សា ឬក្រោយមធ្យមសិក្សា។ ប្រមាណជា១២% នៃស្ត្រី និង ៦% នៃបុរសមិនបានចូលសាលា ។

## ៣.៣ លទ្ធភាពមានកូន

**លទ្ធភាពមានកូនសរុប**

ជាចំនួនកូនមធ្យមដែលស្ត្រីម្នាក់អាចមាននៅចុងបញ្ចប់វ័យបន្តពូជ ប្រសិនបើនាងបង្កើតកូនតាមអត្រានៃលទ្ធភាពមានកូនតាមអាយុជាក់លាក់នាពេលបច្ចុប្បន្ន។

អត្រាលទ្ធភាពមានកូនតាមអាយុជាក់លាក់ត្រូវបានគណនាសម្រាប់រយៈពេល ៣ ឆ្នាំមុនពេលអង្កេត ដោយផ្អែកលើប្រវត្តិមានពរពោះផ្តល់ដោយស្ត្រី។

*សម្រាប់: ស្ត្រីអាយុ ១៥-៤៩ ឆ្នាំ*

តារាង ៣ បង្ហាញអត្រាលទ្ធភាពមានកូនតាមក្រុមអាយុជាក់លាក់ (ASFRs) របស់ស្ត្រីតាមក្រុមអាយុ ៥ ឆ្នាំសម្រាប់រយៈពេល ៣ ឆ្នាំមុនអង្កេត និងអត្រានៃលទ្ធភាពមានកូនសរុប (TFR) ។

- ប្រសិនលទ្ធភាពមានកូននៅតែស្ថិតស្ថេរក្នុងកម្រិតបច្ចុប្បន្ន ស្ត្រីកម្ពុជានឹងមានកូនជាមធ្យមចំនួន ២.៧ នាក់ក្នុងពេញមួយជីវិត។
- លទ្ធភាពមានកូនមានអត្រាទាបចំណោមវ័យជំទង់ (៤៨ កំណើតក្នុងចំណោមស្ត្រី ១.០០០ នាក់ដែលមានអាយុ១៥-១៩ ឆ្នាំ) អត្រាលទ្ធភាពមានកូនខ្ពស់បំផុត ១៥៤ ឆ្នាំចំណោមស្ត្រី ១.០០០ នាក់ដែលមានអាយុ ២០-២៤ ឆ្នាំ ហើយបន្តបន្ទាប់ ។

<u>តារាង ៣ លទ្ធភាពបង្កើតកូនបច្ចុប្បន្ន</u>

អត្រានៃលទ្ធភាពមានកូនតាមក្រុមអាយុជាក់លាក់ និង អត្រានៃលទ្ធភាពមានកូនសរុប អត្រាបង្កើតកូនទូទៅ អត្រាកំណើតដុលសម្រាប់រយៈពេលបីឆ្នាំមុនអង្កេតតាមតំបន់ កម្ពុជា ២០២១-២២

| | តំបន់ | | |
|---|---|---|---|
| ក្រុមអាយុ | ទីប្រជុំជន | ជនបទ | សរុប |
| 15–19 | 39 | 55 | 48 |
| 20-24 | 128 | 174 | 154 |
| 25-29 | 127 | 166 | 149 |
| 30-34 | 107 | 112 | 110 |
| 35-39 | 57 | 64 | 61 |
| 40-44 | 23 | 24 | 24 |
| 45-49 | [3] | [3] | [3] |
| TFR (15–49) | 2.4 | 3.0 | 2.7 |
| GFR | 85 | 100 | 94 |
| CBR | 20.5 | 20.1 | 20.2 |

សម្គាល់:អត្រាលទ្ធភាពបង្កើតកូនអាយុជាក់លាក់ក្នុងចំណោមស្ត្រី ១.០០០នាក់ ។ ការគណនាអត្រានេះសម្រាប់រយៈពេល១-៣៦ ខែមុនការធ្វើអង្កេត ។

TFR អត្រាលទ្ធភាពបង្កើតកូនសរុបសំដៅលើស្ត្រីម្នាក់ៗ

GFR: ត្រាលទ្ធភាពបង្កើតកូនទូទៅសំដៅលើស្ត្រី ១.០០០ នាក់ដែលមានអាយុ ១៥-៤៤

CBR: អត្រាកំណើតដុលគណនាផ្អែកលើចំនួនប្រជាជនសរុប ១.០០០ នាក់អត្រាកំណើតដុល

## និន្នាការ:

ជាទូទៅអត្រាលទ្ធភាពមានកូនសរុបបានធ្លាក់ចុះពី ៣.៨ កំណើតក្នុងស្ត្រីម្នាក់ក្នុងឆ្នាំ ២០០០ ដល់ ២.៧ កំណើតក្នុងឆ្នាំ ២០១៤ ហើយមិនផ្លាស់ប្តូរនៅឆ្នាំ ២០២១-២២ (រូបភាពទី ១)។ ការផ្លាស់ប្តូរអត្រាលទ្ធភាពមានកូនសរុបនៅទីប្រជុំជន និងជនបទរវាងឆ្នាំ ២០១៤ និង ២០២១-២០២២ គឺដោយសារការធ្វើចំណាត់ថ្នាក់ឡើងវិញនៅក្នុងជំរឿនប្រជាជនទូទៅឆ្នាំ ២០១៩ ដែល EAs ២០% នៅជនបទក្លាយជា EAs នៅទីប្រជុំជន ។

### រូប ១ និន្នាការអត្រាលទ្ធភាពមានកូនសរុបតាមតំបន់

អត្រាលទ្ធភាពមានកូនសរុបសម្រាប់រយៈពេល ៣ ឆ្នាំមុនអង្កេត



## ៣.៤ លទ្ធភាពមានកូនវ័យជំទង់

**ការមានគភ៌វ័យជំទង់**

ជាភាគរយស្ត្រីអាយុ ១៥-១៩ ដែលធ្លាប់ការមានគភ៌ និងមាតុភាពវ័យជំទង់

*សម្រាប់: ស្ត្រីអាយុ ១៥-១៩ ឆ្នាំ*

តារាង ៤ បង្ហាញភាគរយស្ត្រីអាយុ ១៥-១៩ ឆ្នាំ ដែលធ្លាប់មានផ្ទៃពោះអំឡុងពេលអង្កេត តាមលក្ខណៈចរឹតលក្ខណៈអង្កេត។

តារាង ៤ ការមានគភ៌ និងមាតុភាពវ័យជំទង់

ភាគរយស្ត្រីអាយុ ១៥-១៩ ឆ្នាំធ្លាប់សម្រាលកូនរស់ ធ្លាប់រលូត/រំលូត មានគភ៌កូនដំបូងនិងធ្លាប់មានគភ៌តាមចរឹតលក្ខណៈអង្កេត កម្ពុជាឆ្នាំ ២០២១-២២

| ចរឹតលក្ខណៈអង្កេត | ភាគរយស្ត្រីអាយុ ១៥-១៩ | | | | |
|---|---|---|---|---|---|
| | ធ្លាប់សម្រាលកូនរួច | ធ្លាប់រលូត /រំលូត [1] | កំពុងពរពោះ | ធ្លាប់ពរពោះ | ចំនួនស្ត្រី |
| **អាយុ** | | | | | |
| 15 | 0.4 | 0.0 | 0.8 | 1.2 | 670 |
| 16 | 1.7 | 0.0 | 0.9 | 2.7 | 692 |
| 17 | 4.0 | 1.0 | 1.6 | 6.4 | 631 |
| 18 | 10.5 | 2.4 | 2.9 | 14.0 | 540 |
| 19 | 22.2 | 6.8 | 8.5 | 30.2 | 448 |
| **តំបន់** | | | | | |
| ទីប្រជុំជន | 5.2 | 3.0 | 2.2 | 8.3 | 1,144 |
| ជនបទ | 7.5 | 0.9 | 2.7 | 10.0 | 1,837 |
| **រាជធានី ខេត្ត** | | | | | |
| បន្ទាយមានជ័យ | 8.1 | 1.3 | 2.3 | 11.7 | 154 |
| បាត់ដំបង | 5.4 | 1.5 | 2.9 | 8.3 | 224 |
| កំពង់ចាម | 4.2 | 0.0 | 1.2 | 5.4 | 168 |
| កំពង់ឆ្នាំង | 9.1 | 0.7 | 2.8 | 11.0 | 103 |
| កំពង់ស្ពឺ | 4.4 | 2.5 | 2.2 | 7.5 | 175 |
| កំពង់ធំ | 5.1 | 2.9 | 1.3 | 7.5 | 129 |
| កំពត | 4.4 | 0.6 | 2.5 | 7.0 | 132 |
| កណ្ដាល | 3.5 | 2.0 | 0.9 | 4.4 | 228 |
| កោះកុង | 9.1 | 1.3 | 5.0 | 15.4 | 22 |
| ក្រចេះ | 11.9 | 0.0 | 5.6 | 14.6 | 66 |
| មណ្ឌលគិរី | 9.2 | 1.0 | 2.6 | 11.7 | 20 |
| ភ្នំពេញ | 6.3 | 3.3 | 2.5 | 9.7 | 421 |
| ព្រះវិហារ | 13.3 | 2.1 | 2.3 | 15.6 | 58 |
| ព្រៃវែង | 5.9 | 0.9 | 1.8 | 7.4 | 192 |
| ពោធិសាត់ | 5.2 | 0.0 | 3.5 | 8.7 | 57 |
| រតនគិរី | 17.1 | 1.1 | 1.3 | 18.4 | 54 |

| | | | | | |
|---|---|---|---|---|---|
| សៀមរាប | 6.5 | 0.6 | 3.2 | 9.7 | 216 |
| ព្រះសីហនុ | 7.3 | 3.3 | 4.8 | 13.8 | 33 |
| ស្ទឹងត្រែង | 17.3 | 4.0 | 7.9 | 24.6 | 39 |
| ស្វាយរៀង | 7.5 | 4.5 | 1.0 | 9.6 | 101 |
| តាកែវ | 5.1 | 1.3 | 2.9 | 7.9 | 197 |
| ឧត្តរមានជ័យ | 5.5 | 1.0 | 3.4 | 9.9 | 33 |
| កែប | 7.1 | 1.6 | 1.5 | 9.6 | 8 |
| ប៉ៃលិន | 9.5 | 3.2 | 4.8 | 14.3 | 16 |
| ត្បូងឃ្មុំ | 10.0 | 0.6 | 4.4 | 13.6 | 135 |
| **កម្រិតសិក្សាអប់រំ** | | | | | |
| មិនបានចូលសាលា | 31.8 | 3.6 | 5.4 | 35.2 | 50 |
| បឋមសិក្សា | 14.0 | 2.9 | 6.3 | 20.6 | 532 |
| មធ្យមសិក្សា | 4.6 | 1.4 | 1.7 | 6.5 | 2,320 |
| ខ្ពស់ជាងមធ្យមសិក្សា | 0.0 | 0.0 | 0.0 | 0.0 | 80 |
| **បញ្ចភាគទ្រព្យសម្បត្តិ** | | | | | |
| ទាបបំផុត | 11.5 | 2.0 | 5.2 | 16.3 | 530 |
| ទាប | 6.9 | 0.0 | 1.6 | 8.4 | 610 |
| មធ្យម | 6.0 | 2.5 | 3.4 | 10.2 | 587 |
| ខ្ពស់ | 5.5 | 2.2 | 2.4 | 8.5 | 680 |
| ខ្ពស់បំផុត | 3.7 | 1.9 | 0.4 | 4.1 | 573 |
| សរុប | 6.6 | 1.7 | 2.5 | 9.3 | 2,981 |

[1] កូនកើតរស់, ធ្លាប់រលូត ឬ រំលូត

- ជារួមស្ត្រីអាយុ ១៥-១៩ ឆ្នាំធ្លាប់ពរពោះមាន ៩% បានសម្រាលកូនរួចមាន ៧% បានបាត់បង់ការពរពោះ(រំលូត ឬរលូត)មាន ២% និងបច្ចុប្បន្នកំពុងពរពោះមាន ៣% ។
- ភាគរយស្ត្រីអាយុ ១៥-១៩ ឆ្នាំធ្លាប់ពរពោះកើនឡើងតាមអាយុពី ២% នៅអាយុ ១៥ ឆ្នាំទៅ ៣០% នៅអាយុ ១៩ ឆ្នាំ។
- ស្ត្រីអាយុ ១៥-១៩ ឆ្នាំធ្លាប់មានគភ៌គឺមានទំនាក់ទំនងនឹងការខ្វះការអប់រំ ៣៥% នៃវ័យជំទង់ដែលមិនបានចូលសាលាធ្លាប់ពរពោះធៀបនឹង ៧% មានកម្រិតអប់រំមធ្យមសិក្សា និង ០% មានកម្រិតអប់រំខ្ពស់ជាងមធ្យមសិក្សា។

## ៣.៥ ចំណង់ចំណូលចិត្តបង្កើតកំណើត

**ការសម្រេចចិត្តយកកូនមួយទៀត**
ស្ត្រីត្រូវបានសួរសំណួរតើអ្នកចង់បានកូនច្រើន ឬអត់ ហើយប្រសិនបើនាងចង់តើអ្នកចង់រង់ចាំយូរប៉ុណ្ណាក្នុងការយកកូនបន្ទាប់។ ស្ត្រីដែលបញ្ឈប់កំណើតអចិន្ត្រៃយ៍ត្រូវបានសន្មត់ថាមិនចង់បានកូនទៀតទេ។
*សម្រាប់: ស្ត្រីអាយុ ១៥-១៩ ឆ្នាំបច្ចុប្បន្នរៀបការ*

តារាងទី ៥ បង្ហាញពីចំណង់ចំណូលចិត្តក្នុងការមានកូនក្នុងចំណោមស្ត្រីបច្ចុប្បន្នរៀបការអាយុ ១៥-៤៩ តាមចំនួនកូនកើតរស់។

- ១៤% នៃស្ត្រីចង់បានកូនម្នាក់ទៀតឆាប់ៗ (រយៈពេល ២ ឆ្នាំខាងមុខ) និង ១៧% ចង់មានកូនមួយទៀតនៅពេលក្រោយ (រយៈពេល ២ ឆ្នាំ ឬលើសពីនេះ) និង ៣% ចង់បានកូនមួយទៀតប៉ុន្តែមិនទាន់សម្រេចចិត្តនៅពេលណា ។
- ៥០% នៃស្ត្រីមិនចង់មានកូនទៀតទេ ៤% បានបញ្ឈប់កំណើតអចិន្ត្រៃយ៍ ៣% មានជំងឺមិនមានលទ្ធភាពពរពោះ។
- ភាគរយស្ត្រីដែលមិនចង់មានកូនបន្តទៀតបានកើនឡើងជាមួយនឹងចំនួនកូនរស់ដែលនាងមានពី ៥% មិនមានកូននៅរស់រហូតដល់ ៨២% នៃស្ត្រីដែលមានកូនចាប់ពី ៦ នាក់ឡើង។

តារាង ៥ ចំណង់ចំណូលចិត្តបង្កើតកំណើតរបស់ស្ត្រីតាមចំនួនកូនកើតរស់

ភាគរយស្ត្រីបច្ចុប្បន្នរៀបការអាយុ ១៥-៤៩ សម្រេចចិត្តមានកូនតាមចំនួនកូនកើតរស់ CDHS ២០២១–២២

| ការសម្រេចចិត្តមានកូន | ចំនួនកូនកើតរស់[1] ០ | ១ | ២ | ៣ | ៤ | ៥ | ៦+ | សរុប |
|---|---|---|---|---|---|---|---|---|
| ចង់បានម្នាក់ទៀតឆាប់ៗ [2] | 69.8 | 26.7 | 9.0 | 3.8 | 2.3 | 0.9 | 0.9 | 13.9 |
| ចង់បានម្នាក់ទៀតពេលក្រោយ [3] | 10.2 | 40.2 | 16.5 | 4.9 | 1.9 | 0.8 | 0.0 | 16.8 |
| ចង់បានម្នាក់ទៀតតែមិនដឹងពេលណា | 2.5 | 5.7 | 3.1 | 1.6 | 0.8 | 0.5 | 0.0 | 3.0 |
| មិនទាន់សម្រេចចិត្តនៅឡើយ | 6.0 | 10.6 | 11.8 | 8.6 | 6.7 | 6.3 | 3.5 | 9.8 |
| មិនចង់បានម្នាក់ទៀតទេ | 4.9 | 13.2 | 54.3 | 72.5 | 77.4 | 82.8 | 82.0 | 50.1 |
| បញ្ឈប់កំណើតអចិន្ត្រៃយ៍ [4] | 0.3 | 0.6 | 2.3 | 5.4 | 7.6 | 4.6 | 9.4 | 3.2 |
| ជំងឺមិនមានលទ្ធភាពពរពោះ | 6.3 | 3.0 | 2.9 | 3.2 | 3.2 | 4.1 | 4.2 | 3.3 |
| សរុប | 100.0 | 100.0 | 100.0 | 100.0 | 100.0 | 100.0 | 100.0 | 100.0 |
| ចំនួនស្ត្រី | 697 | 2,966 | 5,029 | 3,070 | 1,091 | 424 | 216 | 13,492 |

[1] ចំនួនកូនកើតរស់រួមទាំងការមានផ្ទៃពោះពេលបច្ចុប្បន្ន

[2] ចង់កំណើតបន្ទាប់ក្រោយក្នុងរយៈពេលពីរឆ្នាំ

[3] ចង់ពន្យាពេលកំណើតបន្ទាប់ពីរ ឬច្រើនឆ្នាំទៀត

[4] 4 រួមបញ្ចូលទាំងការបញ្ឈប់កំណើតអចិន្ត្រៃយ៍របស់បុរសនិងស្ត្រី

## ៣.៦ ផែនការគ្រួសារ

### ៣.៦.១ ការប្រើប្រាស់វិធីសាស្ត្រពន្យាកំណើត

**ប្រេវ៉ាឡង់ការប្រើប្រាស់វិធីសាស្ត្រពន្យាកំណើត**

ជាភាគរយស្ត្រីដែលប្រើប្រាស់វិធីសាស្ត្រពន្យាកំណើតណាមួយ។

**សម្រាប់: ស្ត្រីអាយុ ១៥-៤៩ ឆ្នាំបច្ចុប្បន្នរៀបការ និងសកម្មរួមភេទសម្រាប់ស្ត្រីមិនរៀបការអាយុ ១៥-៤៩**

**វិធីសាស្ត្រពន្យាកំណើតទំនើប**

រួមបញ្ចូលការបញ្ចប់កំណើតអចិន្ត្រៃយ៍បុរស និងស្ត្រី ថ្នាំចាក់ កងដាក់ក្នុងស្បូន (IUD) ថ្នាំគ្រាប់ កងដាក់ក្រោមស្បែក ស្រោមអនាម័យស្ត្រី និងបុរស ថ្នាំគ្រាប់ការពារកំណើតបន្ទាន់តាមវិធីបទដ្ឋានថ្ងៃ និងវិធីសាស្ត្របំបៅកូនដោយទឹកដោះម្តាយ។

តារាងទី ៦ បង្ហាញពីការប្រើវិធីសាស្ត្រពន្យារកំណើតក្នុងចំណោមស្ត្រីបច្ចុប្បន្នរៀបការ និងស្ត្រីមានដៃគូរួមភេទ និងស្ត្រីមិនទាន់រៀបការ។

- ហុកសិបពីរភាគរយនៃស្ត្រីបច្ចុប្បន្នរៀបការកំពុងប្រើវិធីពន្យារកំណើតក្នុងនោះ ៤៥% កំពុងប្រើវិធីសាស្ត្រទំនើប និង ១៧% កំពុងប្រើវិធីសាស្ត្របុរាណ។
- ក្នុងចំណោមស្ត្រីបច្ចុប្បន្នរៀបការ ថ្នាំគ្រាប់ពន្យារកំណើតជាវិធីសាស្ត្រទំនើបដែលគេប្រើច្រើនបំផុត (២៦%) បន្ទាប់មកដោយថ្នាំចាក់ (៦%) និង កងដាក់ក្នុងស្បូន (៥%) ។
- បើទោះជាស្ត្រីបច្ចុប្បន្នរៀបការនៅទីប្រជុំជនបានប្រើវិធីពន្យារកំណើតណាមួយជាងស្ត្រីនៅជនបទក៏ដោយ(៦៦% ធៀបនឹង ៥៩%) ក៏ស្ត្រីនៅតំបន់ជនបទបានប្រើវិធីសាស្ត្រទំនើបខ្ពស់ជាងស្ត្រីនៅទីប្រជុំជន (៤៧% ធៀបនឹង ៤១%)។ វិធីសាស្ត្រពន្យារកំណើតតាមបែបប្រពៃណីក្នុងចំណោមស្ត្រីបច្ចុប្បន្នរៀបកាខ្ពស់ជាងនៅតំប្រជុំជន (២៤%) ជាងនៅជនបទ (១២%)។

តារាង ៦ វិធីសាស្ត្រពន្យារកំណើតបច្ចុប្បន្នតាមចរិតលក្ខណៈអង្កេត

*ភាគរយស្ត្រីរៀបការ និងសកម្មរួមភេទសម្រាប់ស្ត្រីមិនរៀបការអាយុ ១៥-៤៩ ឆ្នាំកំពុងប្រើវិធីសាស្ត្រពន្យារកំណើតបច្ចុប្បន្នតាមចរិតលក្ខណៈអង្កេតកម្ពុជា ឆ្នាំ២០២១-២២*

| ចរិតលក្ខណៈអង្កេត | វិធីសាស្ត្រណាមួយ | វិធីសាស្ត្រទំនើប | វិធីសាស្ត្រទំនើប: ចោះចង បញ្ឈប់កំណើតស្ត្រី | កងដាក់ក្នុងស្បូន IUD | ថ្នាំចាក់ | កងដាក់ក្រោមស្បែក | ថ្នាំគ្រាប់លេបប្រចាំថ្ងៃ | ស្រោមបុរស | *វិធីសាស្ត្របទដ្ឋាន ការរាប់ថ្ងៃ* | ផ្សេងទៀត | វិធីសាស្ត្របុរាណ | វិធីសាស្ត្របុរាណ: វិធីសាស្ត្ររាប់ថ្ងៃ | ដកលិង្គចេញ | មិនបានប្រើ | សរុប | ចំនួនស្ត្រី |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| **ចំនួនកូនរស់** | | | | | | | | | | | | | | | | |
| 0 | 13.5 | 4.7 | 0.2 | 0.1 | 0.7 | 0.0 | 2.5 | 0.8 | 0.4 | 0.0 | 8.8 | 0.7 | 8.1 | 86.5 | 100.0 | 963 |
| 1-2 | 65.0 | 46.7 | 1.7 | 5.1 | 6.2 | 2.2 | 28.4 | 1.9 | 0.9 | 0.2 | 18.3 | 1.1 | 17.2 | 35.0 | 100.0 | 7,933 |
| 3-4 | 68.3 | 50.6 | 6.2 | 6.5 | 7.0 | 2.3 | 25.7 | 1.7 | 1.2 | 0.1 | 17.7 | 0.9 | 16.8 | 31.7 | 100.0 | 3,966 |
| 5+ | 57.7 | 44.0 | 6.1 | 4.6 | 7.3 | 2.7 | 21.3 | 1.4 | 0.5 | 0.2 | 13.7 | 1.3 | 12.4 | 42.3 | 100.0 | 630 |
| **អាយុ** | | | | | | | | | | | | | | | | |
| 15-19 | 40.9 | 31.7 | 0.0 | 2.8 | 6.1 | 1.1 | 20.2 | 1.5 | 0.0 | 0.0 | 9.3 | 0.7 | 8.5 | 59.1 | 100.0 | 335 |
| 20-24 | 52.9 | 39.7 | 0.1 | 2.2 | 7.5 | 1.8 | 26.4 | 1.3 | 0.4 | 0.1 | 13.2 | 0.8 | 12.4 | 47.1 | 100.0 | 1,384 |
| 25-29 | 61.8 | 44.6 | 0.5 | 3.5 | 6.6 | 2.4 | 29.3 | 1.4 | 0.4 | 0.5 | 17.2 | 0.7 | 16.5 | 38.2 | 100.0 | 2,365 |
| 30-34 | 67.7 | 47.3 | 1.7 | 6.0 | 5.8 | 1.9 | 28.5 | 1.8 | 1.5 | 0.1 | 20.4 | 1.4 | 18.9 | 32.3 | 100.0 | 2,840 |
| 35-39 | 72.8 | 54.9 | 4.6 | 7.3 | 6.8 | 3.1 | 30.1 | 2.0 | 0.9 | 0.1 | 17.9 | 0.9 | 17.0 | 27.2 | 100.0 | 2,902 |
| 40-44 | 63.0 | 45.3 | 6.1 | 6.3 | 5.9 | 1.7 | 21.6 | 2.5 | 1.1 | 0.1 | 17.7 | 1.2 | 16.5 | 37.0 | 100.0 | 2,262 |
| 45-49 | 40.3 | 25.5 | 6.0 | 3.2 | 3.2 | 1.3 | 9.8 | 0.5 | 1.5 | 0.1 | 14.7 | 1.2 | 13.5 | 59.7 | 100.0 | 1,404 |
| **តំបន់** | | | | | | | | | | | | | | | | |
| ទីប្រជុំជន | 65.9 | 41.4 | 3.4 | 6.2 | 3.0 | 1.9 | 23.2 | 2.7 | 0.9 | 0.2 | 24.4 | 1.8 | 22.7 | 34.1 | 100.0 | 5,404 |
| ជនបទ | 59.3 | 46.9 | 2.9 | 4.4 | 8.2 | 2.3 | 27.0 | 1.1 | 1.0 | 0.1 | 12.4 | 0.6 | 11.9 | 40.7 | 100.0 | 8,088 |
| **រាជធានី ខេត្ត** | | | | | | | | | | | | | | | | |
| បន្ទាយមានជ័យ | 62.2 | 56.2 | 3.5 | 3.0 | 11.4 | 3.0 | 33.2 | 1.4 | 0.6 | 0.0 | 6.0 | 0.3 | 5.6 | 37.8 | 100.0 | 497 |
| បាត់ដំបង | 65.5 | 51.1 | 6.4 | 7.6 | 6.4 | 2.4 | 23.6 | 2.8 | 1.9 | 0.0 | 14.4 | 0.6 | 13.8 | 34.5 | 100.0 | 913 |

| | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| កំពង់ចាម | 46.4 | 38.9 | 3.4 | 6.0 | 8.0 | 2.2 | 17.0 | 1.5 | 0.7 | 0.0 | 7.5 | 0.0 | 7.5 | 53.6 | 100.0 | 848 |
| កំពង់ឆ្នាំង | 61.9 | 43.7 | 2.1 | 4.1 | 9.8 | 0.6 | 25.8 | 0.3 | 0.3 | 0.7 | 18.2 | 0.0 | 18.2 | 38.1 | 100.0 | 456 |
| កំពង់ស្ពឺ | 61.8 | 45.3 | 1.7 | 3.0 | 3.9 | 0.7 | 35.0 | 0.5 | 0.0 | 0.4 | 16.6 | 0.1 | 16.5 | 38.2 | 100.0 | 839 |
